លីកាដូ

LICADHO

# សម្ព័ន្ធខ្មែរជំរឿន និង ការពារសិទ្ធិមនុស្ស លីកាដូ

**ខែ មិថុនា ឆ្នាំ ២០០៣**

***របាយការណ៍សង្ខេប***

## ការធ្វើទារុណកម្មនៅក្នុងកន្លែងឃុំឃាំងរបស់ប៉ូលីសនៅកម្ពុជា

របាយការណ៍សង្ខេបនេះ ពិនិត្យមើលទៅលើចារិត វិសាលភាព និងអ្វីដែលអាចជាបុព្វហេតុនៃការធ្វើទារុណកម្មក្នុងកន្លែងឃុំឃាំងរបស់ប៉ូលីសនៅក្នុងប្រទេសកម្ពុជា ក្នុងអំឡុងឆ្នាំ ២០០១ និង២០០២ ។ យើងសង្ឃឹមថា ពត៌មាននៅក្នុងរបាយការណ៍នេះនឹងត្រូវបានប្រើប្រាស់ដើម្បីបំផុសនូវការយល់ដឹងអំពីស្ថានភាពនៃការធ្វើទារុណកម្មនៅក្នុងកន្លែងឃុំឃាំងរបស់ប៉ូលីសក្នុងចំណោមមន្ត្រីរដ្ឋាភិបាល និងសាធារណជនទូទៅដើម្បីបង្ហាញនូវតម្រូវការសំរាប់វិធីជាជំរើសផ្សេងៗទៀតក្នុងការស៊ើបអង្កេតលើបទព្រហ្មទណ្ឌដោយមន្ត្រីប៉ូលីស និងដើម្បីជំរុញឱ្យមានការត្រួតពិនិត្យមើលប្រកបដោយឯករាជ្យ និងទៀងទាត់នៅក្នុងមន្ទីរឃុំឃាំងរបស់ប៉ូលីសដើម្បីកាត់បន្ថយនូវការអនុវត្តន៏ការធ្វើទារុណកម្ម ។

របាយការណ៍សង្ខេបនេះ ធ្វើឡើងដោយផ្អែកទៅលើបទសម្ភាសន៏ជាមួយមនុស្សដែលបានជាប់ឃុំនៅក្នុងពន្ធនាគារនៅកម្ពុជា និងផ្អែកលើការស្រាវជ្រាវផ្សេងៗដែលធ្វើឡើងដោយអង្គការលីកាដូ ។ អាស្រ័យដោយវាមិនមែនជាឯកសារដែលលើកឡើងល្អិតល្អន់អំពីបញ្ហានេះ នោះស្ថិតិនៅក្នុងរបាយការណ៍នេះគ្រាន់តែផ្តល់នូវសន្ទស្សន៏នៃចំនួនមនុស្ស ដែលបានទទួលរងនូវធ្វើទារុណកម្មនៅក្នុងកន្លែងឃុំឃាំងរបស់ប៉ូលីសតែប៉ុណ្ណោះ។ តួលេខពិតប្រាកដប្រហែលជាច្រើនជាងនេះ អាស្រ័យដោយហេតុផលដូចមានរៀបរាប់នៅខាងក្រោមនេះ ។ ការរកឃើញរបស់អង្គការលីកាដូបង្ហាញនូវការប្រើប្រាស់របៀបនៃការធ្វើទារុណកម្មដែលជាវិធីនៃការស៊ើបអង្កេតរបស់ប៉ូលីសនៅទូទាំងប្រទេសកម្ពុជា ដែលក្នុងនោះរួមមានកងរាជអាវុធហត្ថផងដែរ ។ ការធ្វើទារុណកម្មត្រូវបានគេធ្វើឡើងជាបឋមដើម្បីបង្ខំអោយជនជាប់សង្ស័យពីបទព្រហ្មទណ្ឌឆ្លើយសារភាព ដើម្បីជម្រិតយកលុយពីពួកគេ និងដើម្បីជាការដាក់ទណ្ឌកម្មដល់ពួកគេពីបទល្មើសដែលបានចោទប្រកាន់។

ភាពគ្រោះថ្នាក់នៃការធ្វើទារុណកម្មទៅលើមនុស្សដែលត្រូវគេចាប់ខ្លួន មានចំនួនកាន់តែកើនឡើងអាស្រ័យដោយប្រការដែលថា ពួកគេជាញឹកញាប់ត្រូវបានគេឃុំឃាំងនៅក្នុងកន្លែងឃុំឃាំងរបស់ប៉ូលីសដោយមិនមានទំនាក់ទំនងជាមួយនរណាម្នាក់ ដោយគេមិនអោយជួបសមាជិកគ្រួសារ មេធាវី ឬបុគ្គលិកសិទ្ធិមនុស្ស ឬបុគ្គលិកសុខាភិបាល ។ បញ្ហានេះរឹតតែធ្ងន់ធ្ងរទៅទៀត ដោយហេតុថា វាមិនមាន

ការពិនិត្យអោយបានល្អិតល្អន់ប្រកបដោយឯករាជ្យ ឬគ្មានទាល់តែសោះទៅលើស្ថានភាពនៃការឃុំឃាំង ។ ហេតុដូច្នេះ អង្គការលីកាសូមផ្តល់ជាយោបល់ដើម្បីអោយរាជរដ្ឋាភិបាលកម្ពុជា ទីភ្នាក់ងារផ្តល់ជំនួយ និងក្រុមអង្គការសិទ្ធិមនុស្សកម្ពុជា និងអន្តរជាតិ ដើម្បីចាត់វិធានការក្នុងការការពារជនជាប់សង្ស័យដែលជាប់ឃុំឃាំង និងជាពិសេសដើម្បីគាំទ្រនូវតម្រូវការជាបន្ទាន់ឱ្យមានការត្រួតពិនិត្យមួយប្រកបដោយឯករាជ្យនៅក្នុងស្ថានីយ៍ប៉ូលីស ដែលជាមធ្យោបាយមួយក្នុងការទប់ស្កាត់ការធ្វើទារុណកម្ម ។ ឥទ្ធិពលជាវិជ្ជមាននៃការធ្វើការត្រួតពិនិត្យពីខាងក្រៅត្រូវបានបង្ហាញដោយពន្ធនាគារនៅកម្ពុជា ដែលជាទូទៅបើកឱ្យមានការពិនិត្យដោយអង្គការសិទ្ធិមនុស្ស គ្រូពេទ្យ និងអង្គការផ្សេងៗទៀត ។ ការពិនិត្យដោយល្អិតល្អន់ជាប្រក្រតីពីខាងក្រៅនូវស្ថានភាពពន្ធនាគារបានធ្វើអោយមានការថយចុះជាសន្ទឹមៗក្នុងរបាយការណ៍អំពីការធ្វើទារុណកម្ម ដែលប្រព្រឹត្តដោយបុគ្គលិកពន្ធនាគារទៅលើមនុស្សដែលជាប់ឃុំឃាំងក្នុងបណ្តាឆ្នាំថ្មីៗនេះ ។

អង្គការលីកាដូ ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ មានទីស្នាក់ការនៅទីក្រុងភ្នំពេញរាជធានីនៃប្រទេសកម្ពុជា និងមានការិយាល័យនៅតាមខេត្តចំនួន ១២ ទៀត ។ បេសកម្មរបស់អង្គការលីកាដូ រួមមានការស៊ើបអង្កេតទៅលើបទចោទប្រកាន់អំពីការរំលោភសិទ្ធិមនុស្ស ជួយជនរងគ្រោះក្នុងការធ្វើពាក្យបណ្តឹងទៅរដ្ឋអំណាច ការស្រាវជ្រាវ ការតស៊ូមតិ និងផ្តល់ការអប់រំសិទ្ធិមនុស្សដល់ក្រុមគោលដៅផ្សេងៗ។ អ្នកស្រាវជ្រាវរបស់អង្គការលីកាដូបានធ្វើការចុះពិនិត្យជាប្រក្រតីនៅពន្ធនាគារកម្ពុជាដើម្បីតាមដានមើលស្ថានភាពផ្សេងៗ និងសម្ភាសន៍អ្នកជាប់ឃុំឃាំង។

## វិធីសាស្រ្ត និង ព្រំដែនកំណត់

របាយការណ៍នេះផ្អែកទៅលើបទសម្ភាសន៍ដោយអ្នកត្រួតពិនិត្យពន្ធនាគាររបស់លីកាដូ ជាមួយពិរុទ្ធជនជាប់ឃុំឃាំង និងទណ្ឌិតនៅពន្ធនាគារចំនួន ២០កន្លែង នៅទូទាំងប្រទេសកម្ពុជា នៅឆ្នាំ ២០០១ និង ២០០២ ។[១]

ករណីមួយចំនួនតូចទៀត ក៏ត្រូវបានលើកឡើងដោយការដាក់ពាក្យបណ្តឹងដោយផ្ទាល់មកការិយាល័យមួយរបស់លីកាដូ ។ ការស៊ើបអង្កេតនៅតាមមូលដ្ឋានក៏ត្រូវបានធ្វើឡើងនៅក្រុងកំពង់សោមផងដែរ ដើម្បីពិនិត្យមើលឥរិយាបថរបស់ភ្នាក់ងារប៉ូលីស ចំពោះការធ្វើទារុណកម្ម និងចំណេះដឹងរបស់ពួកគេអំពីតម្រូវការឱ្យមានការឃុំឃាំងស្របច្បាប់ ។

---

[១] អាស្រ័យដោយធនធានមានកម្រិត និងកង្វះខាតការិយាល័យអចិន្ត្រៃយ៍ ពន្ធនាគារនៅក្នុងបណ្តាខេត្តខាងក្រោមមិនត្រូវបានបញ្ចូលទៅក្នុងកម្មវិធីត្រួតពិនិត្យពន្ធនាគាររបស់លីកាដូឡើយ។ ខេត្តទាំងនោះ រួមមាន រតនគីរី មណ្ឌលគីរី ក្រចេះ ស្ទឹងត្រែ និង ព្រះវិហារ ។

ចំនួននៃអំពើហិង្សារបស់ប៉ូលីសនៅក្នុងបទសម្ភាសន៍របស់លីកាដូជាមួយអ្នកទោសទំនងជាមិនត្រូវបានគេរាយការណ៍នោះឡើយ អាស្រ័យដោយការសម្ភាសន៍ជាសម្ងាត់ ជាទូទៅមិនត្រូវបានអនុញ្ញាតឡើយ ។ មានតែបទសម្ភាសន៍ចំនួន ២៣ ភាគរយប៉ុណ្ណោះ ដែលត្រូវបានធ្វើឡើងដោយសម្ងាត់ ។ បទសម្ភាសន៍ភាគច្រើនត្រូវបានធ្វើឡើងដោយមានវត្តមានរបស់អ្នកយាមពន្ធនាគារ មន្ត្រីផ្សេងៗ ឬ អ្នកទោសដូចគ្នា ។ អ្នកទោសមួយចំនួនអាចរារែកមិនចង់និយាយ អាស្រ័យដោយមានការភ័យខ្លាចមានការសងសឹកពីបុគ្គលិកពន្ធនាគារ ។ ដូចគ្នានោះដែរ នៅតាមពន្ធនាគារខ្លះមានការពិបាកសម្រាប់អ្នកត្រួតពិនិត្យរបស់អង្គការលីកាដូក្នុងការសុំជួបសម្ភាសន៍ជាមួយជនជាប់ឃុំឃាំងបណ្តោះអាសន្ន ដែលជាក្រុមអ្នកទោសទំនងជាអាចរាយការណ៍អំពីការធ្វើទារុណកម្មរបស់ប៉ូលីសច្រើនជាងគេ ។

ព្រំដែនកំណត់សំខាន់មួយទៀត គឺថាស្ថិតិរបស់លីកាដូអំពីអំពើហិង្សារបស់ប៉ូលីស គឺផ្អែកទៅលើតែមនុស្សដែលត្រូវចាប់ខ្លួន ហើយត្រូវគេដាក់ពន្ធនាគារ ហើយដែលត្រូវបានសម្ភាសន៍ និងឆ្លើយតបចំពោះសំណួរប៉ុណ្ណោះ ។ ស្ថិតិនេះមិនរួមបញ្ចូលមនុស្សដែលត្រូវគេធ្វើទុក្ខបុកម្នេញនៅក្នុងកន្លែងឃុំឃាំងរបស់ប៉ូលីស ប៉ុន្តែត្រូវគេដោះលែងមកវិញដោយហេតុផលណាមួយ ដោយមិនបានបញ្ជូនទៅពន្ធនាគារនោះឡើយ។ មូលហេតុចំបងនៃការពឹងផ្អែកលើពត៌មានអំពីអ្នកទោសដូចគ្នានោះ គឺការដែលអ្នកត្រួតពិនិត្យប្រកបដោយឯករាជ្យមិនអាចចេញ-ចូលកន្លែងឃុំឃាំងរបស់ប៉ូលីសបាន ។ ជាលទ្ធផលនៃកត្តាទាំងនេះ ចំនួនពិតប្រាកដនៃការធ្វើទារុណកម្មដោយប៉ូលីសប្រាកដជាខ្ពស់ជាងស្ថិតិនៅក្នុងរបាយការណ៍នេះ ។

ការអះអាងរបស់អ្នកផ្តល់ចម្លើយភាគច្រើនថាមានការធ្វើទារុណកម្មដោយប៉ូលីស មិនត្រូវបានស៊ើបអង្កេតឡើយ ហើយវាអាចអោយជឿបាន។ ភស្តុតាងនៃការធ្វើទារុណកម្មលើរាងកាយ ជាញឹកញាប់បានជាសះស្បើយនៅពេលដែលអ្នកទោសត្រូវបានសម្ភាសន៍ ទោះបីជាអ្នកត្រួតពិនិត្យរបស់លីកាដូពិតជាបានឃើញមានរបួសស្នាមបញ្ជាក់ថាស៊ីសង្វាក់ជាមួយការធ្វើទារុណកម្មក្តី ។ ការស៊ើបអង្កេតរកពត៌មានបន្ថែមអំពីការចោទប្រកាន់នៃការធ្វើទារុណកម្ម ជាទូទៅមិនត្រូវបានធ្វើឡើងដោយអង្គការលីកាដូឡើយ ប្រសិនបើអ្នកដែលត្រូវបានសម្ភាសន៍មិនបានយល់ព្រមដាក់ពាក្យបណ្តឹងប្រឆាំងនឹងអ្នកធ្វើទារុណកម្មមកលើខ្លួនទេនោះ។ ករណីភាគច្រើន ពួកគេមិនចង់ប្រាប់ពីបញ្ហានេះទេ ព្រោះខ្លាចមានការសងសឹក ។

អាស្រ័យដោយមូលហេតុខាងលើ ស្ថិតិនៅក្នុងរបាយការណ៍នេះគ្រាន់តែជាការប្រាប់ឱ្យដឹងប៉ុណ្ណោះ គឺមិនមែនជាការសន្និដ្ឋានឡើយ ។ ទោះបីជាយ៉ាងណាក្តី ពត៌មានដែលមានកម្រិតបង្ហាញថាការធ្វើទារុណកម្មមកលើជនសង្ស័យនៅក្នុងកន្លែងឃុំឃាំងរបស់ប៉ូលីសមានជាទូទៅ នៅទូទាំងប្រទេសកម្ពុជា។

## និយមន័យនៃការធ្វើទារុណកម្មនៅក្នុងកន្លែងឃុំឃាំងរបស់ប៉ូលីស

ដូចជានៅក្នុងប្រទេសជាច្រើនដែរ ការធ្វើទារុណកម្មមិនត្រូវបានផ្តល់និយមន័យ ឬក៏ចែងជាច្បាប់ថាជាបទល្មើសនៅក្នុងច្បាប់របស់កម្ពុជាឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ ជនល្មើសគួរតែត្រូវបានគេចោទប្រកាន់នៅក្រោមច្បាប់ព្រហ្មទណ្ឌដែលកំពុងអនុវត្ត សំរាប់ធាតុនីមួយៗនៃការធ្វើទារុណកម្ម ឧទាហរណ៍ ការបង្ករបួសស្នាម ការឃុំឃាំងមនុស្សដោយខុសច្បាប់ និងបទមនុស្សឃាត ។ យោងតាមវចនានុក្រមខ្មែរ ដែលចេញផ្សាយដោយពុទ្ធសាសនបណ្ឌិត ពាក្យថា "ទារុណកម្ម" មានន័យថាជា "អំពើកាចសាហាវ អំពើអាក្រក់ និងអំពើអមនុស្សធម៌" ។[២]

និយមន័យផ្លូវច្បាប់អន្តរជាតិដែលអាចប្រើប្រាស់បាននៃពាក្យទារុណកម្ម ដកស្រង់ចេញពីអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងការធ្វើទារុណកម្ម និងការផ្តន្ទាទោស ឬការប្រព្រឹត្តដោយឃោឃៅអមនុស្សធម៌ ឬដែលនាំឱ្យបាត់បង់តម្លៃជាមនុស្ស ដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ននៅឆ្នាំ ១៩៩២ បានចែងថា

*ពាក្យថា "ទារុណកម្ម" មានន័យថា ជាអំពើទាំងឡាយណាដែលនាំឱ្យមានការឈឺចាប់ ឬរងទុក្ខយ៉ាងខ្លាំង ទាំងផ្លូវកាយ ឬផ្លូវចិត្ត ដែលបានបង្កដោយចេតនាទៅលើមនុស្សម្នាក់ក្នុងគោលបំណង ដូចជាដើម្បីយកពត៌មាន ឬចម្លើយសារភាពពីបុគ្គលនោះ ឬពីអ្នកទីបីណាមួយដែលបានប្រព្រឹត្ត ឬគេសង្ស័យថាបានប្រព្រឹត្ត ឬជាការគំរាមកំហែង ឬបង្ខិតបង្ខំបុគ្គលនោះ ឬអ្នកទីបី ឬដើម្បីហេតុផលណាមួយដែលឈរលើមូលដ្ឋានរើសអើងដោយប្រភេទណាមួយក៏ដោយ ពេលណាដែលការឈឺចាប់ ឬការរងទុក្ខនោះត្រូវបានប្រព្រឹត្តឡើងដោយ ឬតាមការញុះញង់ ឬដោយមានការយល់ព្រម ឬការគាំទ្ររបស់អាជ្ញាធរសាធារណៈ ឬអ្នកដទៃណាមួយក្នុងពេលបំពេញកិច្ចការសាធារណៈ ។"*

ចំណុចសំខាន់នៃនិយមន័យនេះគឺថា ការធ្វើទារុណកម្មដែលនាំឱ្យមានការឈឺចាប់ ឬរងទុក្ខយ៉ាងខ្លាំង ទាំងផ្លូវកាយ ឬផ្លូវចិត្ត ដែលបានបង្ក*ដោយចេតនា*។ នៅក្នុងករណីនៃការធ្វើទារុណកម្មដោយប៉ូលីស អ្នកធ្វើទារុណកម្មមានបំណងបង្ករការឈឺចាប់ ជាទូទៅ ដើម្បីបង្ខំយកពត៌មាន ឬចម្លើយសារភាពពីជនរងគ្រោះ។ បើដូចនេះ តើអ្វីទៅដែលហៅថាការរងទុក្ខយ៉ាងខ្លាំង "ធ្ងន់ធ្ងរ" ទាំងផ្លូវកាយ ឬផ្លូវចិត្តនោះ? មិនមានសញ្ញាណសំគាល់ណាមួយជាលក្ខណៈអន្តរជាតិដើម្បីកំណត់នៅពេលដែលអំពើហិង្សា ឬការបំភិតបំភ័យមួយវាក្លាយជា "ធ្ងន់ធ្ងរ" នោះឡើយ ។ វាអាស្រ័យទៅលើការបកស្រាយផ្សេងៗគ្នា ។ ទោះបីជាយ៉ាងណាក្តី អំពើធ្វើទុក្ខបុកម្នេញធូរស្រាលជាងនោះ ដែលប្រហែលជាមិនធ្ងន់ធ្ងរគ្រប់គ្រាន់នឹងត្រូវគេ

---

[២] របាយការណ៍របស់រដ្ឋាភិបាលកម្ពុជា អំពីអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងការធ្វើទារុណកម្ម និងការផ្តន្ទាទោស ឬការប្រព្រឹត្តទាំងឡាយណាដែលឃោរឃៅ អមនុស្សធម៌ ឬដែលនាំឱ្យបាត់បង់តម្លៃជាមនុស្ស ឆ្នាំ២០០៣ ទំព័រ៤

ចាត់ទុកថាជាការធ្វើទារុណកម្មនោះ ក៏ត្រូវបានហាមឃាត់ដោយអនុសញ្ញានេះដែរ ។[៣] សំរាប់គោលបំណងរបស់របាយការណ៍នេះ ពាក្យថា "ទារុណកម្ម" និង "ការធ្វើទុក្ខបុកម្នេញ" អាចត្រូវបានប្រើប្រាស់ជំនួសគ្នាទៅវិញទៅមក អាស្រ័យដោយអំពើទាំងពីរនេះត្រូវបានហាមប្រាមដូចគ្នា ។ ទោះបីជាយ៉ាងណាក្តី ការរំលោភភាគច្រើនដែលត្រូវបានរាយការណ៍ក្នុងបទសម្ភាសន៍របស់លីកាដូជាមួយអ្នកទោស គឺជាអំពើហិង្សាលើរាងកាយធ្ងន់ធ្ងរជាជាងការរំលោភតូចតាច ។

របាយការណ៍នេះ រួមបញ្ចូលការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញនៅក្នុងការឃុំឃាំងរបស់ប៉ូលីសដែលប្រព្រឹត្តិដោយអាជ្ញាធរផ្នែកចាប់ចង ។[៤] វារួមមានដំណាក់កាលផ្សេងៗនៃការស៊ើបអង្កេត ការឆែកឆេរ និងការរឹបអូស ការចាប់ខ្លួន និងការឃុំឃាំងនៅស្ថានីយ៍ប៉ូលីស ដោយមិនគិតថា តើភ្នាក់ងារប៉ូលីសមានអំណាចស្របច្បាប់ដើម្បីធ្វើដូច្នេះ ឬក៏អត់នោះឡើយ ។ ការធ្វើទារុណកម្មដែលប្រព្រឹត្តនៅក្នុងពន្ធនាគារនានាបន្ទាប់ពីអ្នកដែលត្រូវបានគេចាប់ខ្លួន ត្រូវបានបញ្ជូនពីស្ថានីយ៍ប៉ូលីសមិនត្រូវបានរៀបរាប់នៅក្នុងរបាយការណ៍នេះឡើយ ។ ពាក្យថា "ប៉ូលីស" រួមបញ្ចូលទាំងកំលាំងប៉ូលីសស៊ីវិល និងកងតម្រួតយោធា "ឬកងរាជអាវុធហត្ថ" ។ មានអង្គភាពប៉ូលីសស៊ីវិលជាច្រើនដែលរួមមានប៉ូលីសប្រឆាំងគ្រឿងញៀន ប៉ូលីសប្រឆាំងភេរវកម្ម ប៉ូលីសព្រំដែន ប៉ូលីសព្រហ្មទណ្ឌ ។ល។ ជាគោលការណ៍ មានតែអង្គភាពប៉ូលីសពិសេសណាមួយប៉ុណ្ណោះ ដែលត្រូវបានចាត់តាំងជានគរបាលយុត្តិធម៌ ដែលមានអំណាចស្របច្បាប់ក្នុងការចាប់ខ្លួន ឃុំឃាំង ឆែកឆេរ ឬក៏រឹបអូស ។[៥] ទោះបីជាយ៉ាងណាក្នុងការអនុវត្តន៍ជាក់ស្តែងនគរបាលទាំងអស់ប្រើប្រាស់អំណាចបែបនេះ ។ រហូតមកដល់ពេលថ្មីៗនេះ តម្រួតយោធា ឬកងរាជអាវុធហត្ថមានដែនសម្ថកិច្ចធំទូលាយទៅលើបទល្មើសដែលសង្ស័យថាបានប្រព្រឹត្តិដោយ យោធិន *និង ជនស៊ីវិល* ។[៦] កងរាជអាវុធហត្ថមិនត្រូវបានគេអនុញ្ញាតដោយស្របច្បាប់ក្នុងការចាប់ចងជនស៊ីវិលទៀតឡើយ ប៉ុន្តែករណីនេះនៅតែកើតមានជាធម្មតា ។

---

[៣] បន្ថែមពីលើការធ្វើទារុណកម្ម អនុសញ្ញាក៏ហាមប្រាម "ការធ្វើទារុណកម្ម និងការផ្តន្ទាទោស ឬការប្រព្រឹត្តទាំងឡាយណាដែលឃោរឃៅអមនុស្សធម៌ ឬដែលនាំឱ្យបាត់បង់តម្លៃជាមនុស្ស ដែលមិនត្រូវបានគេសន្មត់ថាជាការធ្វើទារុណកម្មទេនោះ" (មាត្រា ១៦) ។ អំពើបែបនេះមិនត្រូវបានកំណត់និយមន័យឡើយ លើកលែងតែប្រការដែលថា វាត្រូវបានប្រព្រឹត្តដោយ ឬដោយជាមួយនឹងការយល់ព្រម ឬការគាំទ្ររបស់មន្ត្រីសាធារណៈណាម្នាក់ ។

[៤] រដ្ឋអំណាចផ្នែកចាប់ចង ជាទូទៅគឺភ្នាក់ងារប៉ូលីស ប៉ុន្តែក្នុងករណីមួយចំនួន គឺជាយោធា ឬមន្ត្រីដទៃទៀត ហើយកន្លែងនៃការឃុំឃាំងមិនមែនជាកន្លែងឃុំឃាំងរបស់ប៉ូលីសទេ គឺជាបន្ទាយយោធា ឬស្ថាប័នផ្សេងទៀត ។

[៥] សូមមើលមាត្រា ៣៦ នៃច្បាប់នីតិវិធីព្រហ្មទណ្ឌ ដែលរៀបរាប់អំពីមន្ត្រីដែលត្រូវបានចាត់ទុកជាភ្នាក់ងារនគរបាលយុត្តិធម៌ ។

[៦] អនុក្រិត្យលេខ ៧៧ ឆ្នាំ១៩៩៤ ស្តីអំពីតួនាទី-ភារកិច្ចនិងរចនាសម្ព័ន្ធទូទៅនៃកងរាជអាវុធហត្ថ ។ ទោះបីជាយ៉ាងណា វិសោធនកម្មទៅលើច្បាប់នីតិវិធីព្រហ្មទណ្ឌ (មាត្រា៣៦) ខែមករា ២០០២ បានកាត់បន្ថយអំណាចរបស់អង្គភាពកងរាជអាវុធហត្ថ ដែលទទួលបន្ទុកផ្នែកព្រហ្មទណ្ឌមកត្រឹមបទល្មើស ដែលទាក់ទងនឹងកិច្ចការយោធាតែប៉ុណ្ណោះ ។

## វិសាលភាពនៃការធ្វើទារុណកម្មរបស់ប៉ូលីសនៅក្នុងកន្លែងឃុំឃាំង

ជនដែលត្រូវគេចាប់ខ្លួន និងឃុំឃាំងនៅកន្លែងឃុំឃាំងរបស់ប៉ូលីសកម្ពុជា ប្រឈមមុខនឹងភាពគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរពីការគំរាមកំហែង ការវាយធ្វើបាប ឬក៏ការធ្វើទារុណកម្ម ជាបឋមដើម្បីបង្ខំយកចម្លើយសារភាពដែលក្រោយមកត្រូវគេប្រើប្រាស់ប្រឆាំងនឹងខ្លួននៅឯតុលាការ ។ យោងតាមការស្រាវជ្រាវរបស់លីកាដូ ការធ្វើទារុណកម្មគឺជាផ្នែកសំខាន់មួយនៃដំណើរការចាប់ខ្លួន និងការស៊ើបអង្កេតនៅទូទាំងប្រទេសកម្ពុជា ។

ក្នុងចំណោមអ្នកទោសចំនួន ៤៧៦៧ នាក់ ដែលត្រូវបានសម្ភាសន៍ដោយលីកាដូ នៅឆ្នាំ២០០១ និង ២០០២ អ្នកទោសចំនួន ៣៨៥ នាក់ (៨%) បានអះអាងថា ខ្លួនត្រូវបានធ្វើទុក្ខបុកម្នេញក្នុងការឃុំឃាំងរបស់ប៉ូលីស បន្ទាប់ពីត្រូវគេចាប់ខ្លួន។[៧] ចំនួនពិតប្រាកដនៃការធ្វើទារុណកម្មរបស់ប៉ូលីសទំនងជាខ្ពស់ជាងតួលេខនេះ អាស្រ័យដោយមូលហេតុដូចដែលបានបញ្ជាក់នៅក្នុងផ្នែកវិធីសាស្ត្រខាងលើ។ អង្គការជំនួយការផ្នែកច្បាប់នៃកម្ពុជា (LAC) ជាអង្គការក្រៅរដ្ឋាភិបាលមួយ ដែលផ្តល់សេវាផ្លូវច្បាប់ដោយឥតគិតថ្លៃចំពោះចុងចោទពីបទព្រហ្មទណ្ឌបានប៉ាន់ប្រមាណថា កូនក្តីរបស់ខ្លួនប្រហែល ៣០% អះអាងថាខ្លួនត្រូវគេវាយធ្វើបាប ឬធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរនៅកន្លែងឃុំឃាំងរបស់ប៉ូលីស។[៨]

ក្នុងចំណោមអ្នកទោសចំនួន ៤៧៦៧ នាក់ ដែលត្រូវបានសម្ភាសន៍ដោយលីកាដូនោះ ពត៌មានអំពីអ្នកទោសចំនួន ៤១៥២ នាក់ (ក្នុងនោះរួមទាំងអ្នកទោស ២៨១ នាក់ នៃអ្នកទោសសរុបចំនួន ៣៨៥ នាក់ ដែលចោទប្រកាន់អំពីការធ្វើទុក្ខបុកម្នេញរបស់ប៉ូលីស) ត្រូវបានធ្វើការវិភាគជាបន្តទៀតដោយលីកាដូ។[៩] ទិន្នន័យអំពីការវិភាគនេះត្រូវបានបង្ហាញខាងក្រោម។

### ទីតាំងភូមិសាស្ត្រនៃការធ្វើទារុណកម្ម

សន្ទស្សន៍នៃវិសាលភាពនៃការធ្វើទារុណកម្ម ដែលបានរកឃើញក្នុងខេត្តនីមួយៗនៅក្នុងប្រទេសកម្ពុជា បានបង្ហាញនៅក្នុងតារាងទី១ ។

---

[៧] បទសម្ភាសន៍រួមមានជាមួយអ្នកជាប់ឃុំបណ្តោះអាសន្ន និងទណ្ឌិត ។ សំណួរដែលសួរគឺៈ "តើអ្នកត្រូវគេបំភិតបំភ័យ គំរាមកំហែង ឬធ្វើទារុណកម្មក្នុងរូបភាពណាមួយដែរឬទេ នៅពេលដែលស្ថិតនៅក្នុងកន្លែងឃុំឃាំងរបស់ប៉ូលីស?" អ្នកដែលឆ្លើយថា "មាន" ត្រូវបានសុំឱ្យពណ៌នាពីការធ្វើទុក្ខបុកម្នេញ ដែលខ្លួនចោទប្រកាន់នោះ ។

[៨] បទសម្ភាសន៍របស់របាយការណ៍នេះជាមួយនិងតំណាង LAC មកពីខេត្ត ចំនួន ៧ គឺៈ កោះកុង កំពង់ចាម ភ្នំពេញ កំពង់សោម សៀមរាប កណ្តាល និងខេត្តស្វាយរៀង ។

[៩] អាស្រ័យដោយធនធានមានកម្រិត កាលពីឆ្នាំ២០០២ ពត៌មានដែលបានមកពីការសម្ភាសន៍អ្នកទោសមិនទាន់ត្រូវបានបញ្ចូលទៅមកក្នុងតារាងទិន្នន័យរបស់លីកាដូនៅឡើយ ហើយមិនអាចធ្វើការវិភាគជាបន្តទៀតនៅឡើយ ។

**តារាងទី១: សមាមាត្រនៃអ្នកជាប់ពន្ធនាគារនៅក្នុងខេត្តនីមួយៗ ដែលត្រូវបានចោទប្រកាន់អំពីការធ្វើទុក្ខបុកម្នេញនៅក្នុងកន្លែងឃុំឃាំងរបស់ប៉ូលីសនៅក្នុងឆ្នាំ ២០០១ និង ២០០២**

| ខេត្ត | ចំនួនអ្នកទោសដែលបានសម្ភាសន៍ | ចំនួនអ្នកទោសដែលចោទប្រកាន់អំពីការធ្វើទុក្ខបុកម្នេញរបស់ប៉ូលីស | ភាគរយនៃការធ្វើទុក្ខបុកម្នេញ |
|---|---|---|---|
| ភ្នំពេញ * | ៣២៧ | ៤៧ | ១៤,៣% |
| កណ្ដាល | ៣៤៣ | ១៦ | ៤,៦% |
| តាកែវ | ១៦៣ | ២២ | ១៣,៥% |
| កំពង់ចាម + | ៤២៨ | ១៦ | ៣,៧% |
| កំពង់ឆ្នាំង | ២៦៧ | ១៥ | ៥,៦% |
| កំពង់ធំ | ២៥១ | ១០ | ៤% |
| កំពង់ស្ពឺ | ១៥២ | ១៨ | ១១,៨% |
| កំពង់សោម | ២០៥ | ២៥ | ១២,២% |
| កំពត | ២៧៤ | ៨ | ២,៩% |
| កោះកុង | ១៦៥ | ៨ | ៤,៨% |
| ព្រៃវែង | ២២០ | ១៧ | ៧,៧% |
| ពោធិសាត់ | ១៣៥ | ៨ | ៥,៩% |
| បាត់ដំបង | ៤៩៣ | ១៤ | ២,៨% |
| បន្ទាយមានជ័យ | ២៦៩ | ១០ | ៣,៧% |
| សៀមរាប | ៣២៩ | ២៨ | ៨,៥% |
| ស្វាយរៀង | ១៣១ | ១៩ | ១៤,៥% |
| **សរុប** | **៤១៥២** | **២៨១** | **៦,៧%** |

បទសម្ភាសន៍ត្រូវបានធ្វើឡើងនៅពន្ធនាគារដូចតទៅ: CC1 (កាលពីមុនហៅថា តេ៣) CC2 (កាលពីមុនហៅថាពន្ធនាគារ ព្រៃស), ទួលស្លែង និងប៉េហ្ស៊ី។ បទសម្ភាសន៍ ត្រូវបានធ្វើឡើងនៅពន្ធនាគារ កំពង់ចាម CC3 (ពីមុនហៅថា តេ៥)។

ក្នុងខណៈដែលខេត្តស្វាយរៀង ភ្នំពេញ និងខេត្តតាកែវ ហាក់ដូចជាការធ្វើទារុណកម្មមានកម្រិតខ្ពស់ ជាពិសេសនោះ ការប្រែប្រួលដែលអាចប៉ះពាល់ដល់ការរកឃើញទាំងនេះ ចាំបាច់ត្រូវយកមកពិចារ

ណា ។ ឧទាហរណ៍ អ្នកទោសប្រហែលជាសុខចិត្តលាតត្រដាងនូវពត៌មានអំពីការធ្វើទារុណកម្មនៅក្នុងខេត្តខ្លះ (កម្រិតនៃការភ័យខ្លាចនៅក្នុងពន្ធនាគារ កម្រិតនៃការសម្ងាត់ក្នុងការសម្ភាសន៍ និង អត្តចរិត និងគុណភាពនៃអ្នកធ្វើបទសម្ភាសន៍អាចជាកត្តាមានឥទ្ធិពល)។ ដោយគ្មានការវិភាគជាបន្តវាមានការពិបាកដើម្បីឱ្យដឹងពិតប្រាកដថា តើខេត្តណាមួយមានការធ្វើទារុណកម្មអាក្រក់បំផុតនោះ។

ទោះបីជាយ៉ាងណាក្តី ពត៌មានដែលមាននេះ បង្ហាញនូវគំរូមួយនៃការធ្វើទារុណកម្មអ្នកទោសជាញឹកញាប់ និងជាយថាក្រមដោយភ្នាក់ងារប៉ូលីសនៅទូទាំងប្រទេស។ គេហាក់ដូចជាយល់ថា វាជាការអនុវត្តធម្មតាទៅហើយ ដែលភ្នាក់ងារប៉ូលីសបង្ខំឱ្យជនជាប់សង្ស័យឆ្លើយសារភាពនោះ។ ការប្រើប្រាស់ការគំរាមកំហែង និងអំពើហិង្សា ព្រមទាំងការដែលប៉ូលីសពឹងផ្អែកទៅលើចម្លើយសារភាពនោះ បង្ហាញឱ្យឃើញនូវអត្រាដ៏ខ្ពស់នៃចម្លើយសារភាព ដែលបានឆ្លើយនៅក្នុងកន្លែងឃុំឃាំងរបស់ប៉ូលីស ។ យោងតាមបទសម្ភាសន៍របស់អង្គលីកាដូ អ្នកជាប់ពន្ធនាគារចំនួនប្រហែល ៩០% បញ្ជាក់ថាពួកគេបានសារភាពក្នុងអំឡុងពេលសួរចម្លើយនៅក្នុងកន្លែងឃុំឃាំងរបស់ប៉ូលីស ។ លើសពីនោះនៅពេលដែលធ្វើអ្នកសម្ភាសន៍សួរថា តើហេតុអ្វីបានជាគេជឿថាពួកគេត្រូវបានធ្វើទុក្ខបុកម្នេញនៅកន្លែងឃុំឃាំងនោះ អ្នកដែលផ្តល់បទសម្ភាសន៍ជាច្រើននាក់បញ្ជាក់ថា ភ្នាក់ងារប៉ូលីសប្រឹងប្រែងស្វែងរកចម្លើយសារភាព ឬក៏ពត៌មានដទៃទៀតអំពីបទល្មើសដែលត្រូវបានចោទប្រកាន់មកលើពួកគេ ។

### ជនរងគ្រោះ

អ្នកទោសភាគច្រើនដែលត្រូវគេវាយធ្វើបាបនៅកន្លែងឃុំឃាំង គឺជាបុរសពេញវ័យ ប៉ុន្តែកុមារ និងស្ត្រីក៏ងាយរងគ្រោះអំពីភាពឃោឃៅរបស់ប៉ូលីសដែរ។ ក្នុងចំណោមអ្នកទោស ២៨១ នាក់ នៅក្នុងក្រុមដែលលើកជាឧទាហរណ៍អំពីអ្នកដែលបានបញ្ជាក់អំពីការធ្វើទុក្ខបុកម្នេញរបស់ប៉ូលីស មានអ្នកទោស ៧ នាក់ ជាស្ត្រី និង ១៥ នាក់ជាកុមារអាយុក្រោម ១៨ ឆ្នាំ។

**ឧទាហរណ៍: ការធ្វើទារុណកម្មមកលើកុមារ**

ក្មេងប្រុសអាយុ១៦ឆ្នាំម្នាក់នៅខេត្តកំពត កំពុងជិះកង់ដែលខ្ចីពីមិត្តភក្តិម្នាក់នៅយប់មួយ នៅពេលដែលអ្នកភូមិដឹងថាក្មេងប្រុសនោះមិនមែនជាម្ចាស់កង់ទេនោះ បានចោទប្រកាន់គេដោយច្រឡំថាបានលួចកង់នោះ ។ ក្មេងប្រុសនោះត្រូវអ្នកភូមិជាច្រើននាក់វាយធ្វើបាប ហើយយកក្មេងនោះទៅប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ ។ ក្នុងរយៈពេល ១២ ម៉ោងក្រោយមកទៀត នគរបាលបានវាយក្មេងប្រុសនោះយ៉ាងហោចណាស់ចំនួន ៤ លើកក្នុងនោះរួមមានការវាយដោយខ្សែក្រវ៉ាត់ ឡើងជាន់ពីលើនៅពេលក្មេងនោះដួលទៅលើដីទាត់ធាក់ក្មេងនោះ ហើយយកកាំភ្លើងវាយទៅលើផ្ទៃមុខរបស់ក្មេងនោះ ។ នៅខណៈមួយនគរបាលជាច្រើននាក់បានបើកបង្អួច ហើយប្រាប់ក្មេងនោះថាប្រសិនបើគេរត់គេចរួចគេនឹងត្រូវរួចខ្លួន។ ក្មេងប្រុសនោះបានចុះតាមបង្អួច ហើយខំប្រឹងរត់បាន ៣០ ម៉ែត្រ មុននឹង

នគរបាលដដែលទៅចាប់ក្មេងនោះមកវិញ ហើយវាយធ្វើបាបទៀត។ នៅថ្ងៃបន្ទាប់មកក្មេងប្រុសនោះត្រូវគេដោះលែងដោយគ្មានធ្វើការចោទប្រកាន់ ក្រោយពេលដែលម្ចាស់កង់បានអះអាងប្រាប់ទៅនគរបាលថាគេបានឱ្យកង់ទៅក្មេងប្រុសនោះខ្ចីទេ។ ក្មេងប្រុសនោះត្រូវសម្រាកក្នុងមន្ទីរពេទ្យចំនួនពីរខែកន្លះ ដើម្បីព្យាបាលមុខរបួស ហើយគេមិនអាចដើររួចអស់ជាងមួយខែ ។ មិនមាននគរបាលណាម្នាក់ ដែលត្រូវបានគេយកមកកាត់ទោស ដោយសារការធ្វើទារុណកម្មនោះឡើយ ។ បន្ទាប់ពីបានទទួលនូវពាក្យបណ្តឹងព្រហ្មទណ្ឌរបស់ឪពុកម្តាយក្មេងនោះ ព្រះរាជអាជ្ញាអមតុលាការម្នាក់មិនបានធ្វើការចោទប្រកាន់ឡើយ ប៉ុន្តែផ្ទុយមកវិញ ព្រះរាជអាជ្ញានោះបានធ្វើកាដោះស្រាយនៅក្រៅផ្លូវតុលាការ ដោយអោយនគរបាលដែលបានប្រព្រឹត្តបទល្មើសបង់ប្រាក់ទៅអោយគ្រួសារជនរងគ្រោះ ។

អ្នកផ្តល់ចម្លើយចំនួន ២៨១ នាក់ ដែលបានចោទប្រកាន់ថាមានការធ្វើទុក្ខបុកម្នេញដោយប៉ូលិសសុទ្ធតែជាជនជាតិកម្ពុជា លើកលែងតែជនបរទេសម្នាក់ដែលជាជនជាតិវៀតណាម។ បទល្មើសដែលចោទប្រកាន់មកលើពួកគេមានចាប់ពីឃាតកម្មរហូតដល់ការនេសាទត្រីខុសច្បាប់ ។ សំណុំរឿងភាគច្រើនពាក់ព័ន្ធនឹងអំពើចោរកម្មឬអំពើប្លន់ ប៉ុន្តែនេះប្រហែលមកពីបទល្មើសទាំងនេះ វាមានជាទូទៅទៅហើយ ។ វាពិបាកនឹងថ្លឹងថ្លែងពីបទល្មើសណាមួយធៀបទៅនឹងកម្រិតនៃការរំលោភបំពានមកលើជនជាប់សង្ស័យ ។ ទោះបីជាយ៉ាងណា វាហាក់ដូចជាថាមានកត្តាជាច្រើនដែលអាចនាំអោយមានការធ្វើទារុណកម្មកាន់តែធ្ងន់ធ្ងរ មានជាអាទិ៍ ប្រការដែលភ្នាក់ងារនគរបាលម្នាក់មិនចូលចិត្តជនជាប់សង្ស័យ ប្រសិនបើជនជាប់សង្ស័យគឺជាឧក្រិដ្ឋជនដែលគេ "ស្គាល់មុខ" ឬក៏ធ្លាប់ជាប់ពន្ធនាគារពីមុនមក ឬប្រសិនបើបងប្អូន ឬមិត្តភក្តិរបស់នគរបាលគឺជាជនរងគ្រោះនៃបទល្មើសដែលគេចោទប្រកាន់មកលើជនដែលជាប់សង្ស័យ ឬក៏ប្រសិនបើនគរបាលកំពុងស្វែងរកពត៌មានបន្ថែមទៀត ដូចជា ឈ្មោះរបស់អ្នកសមគំនិតប្រព្រឹត្តបទល្មើសជាដើម ។ ក្នុងករណីដែលនគរបាលជឿថា ជនជាប់សង្ស័យមានប្រាក់កាស នោះការរំលោភបំពានអាចមានកាន់តែធ្ងន់ធ្ងរទៅទៀតក្នុងគោលបំណងដើម្បីជំរិតយកប្រាក់។

## វិធីក្នុងការធ្វើទារុណកម្ម

ក្នុងចំណោមអ្នកទោសចំនួន ២៨១ នាក់ ដែលចោទប្រកាន់ថាមានការធ្វើទុក្ខបុកម្នេញដោយប៉ូលិស អ្នកទោសភាគច្រើនរៀបរាប់ថាមានអំពីហិង្សាមកលើរាងកាយដ៏ធ្ងន់ធ្ងរ។ វិធីនៃការធ្វើទារុណកម្មដែលពួកគេបានរាយការណ៍អាចចែកជាប្រាំប្រភេទៈ

- វាយ/ទាត់ដោយដៃ ឬស្បែកជើង
- វាយដោយប្រើឧបករណ៍ ( កាំភ្លើង ដំបង ។ល ។)

- រូបភាពផ្សេងៗទៀតនៃការធ្វើទារុណកម្មលើរាងកាយ ដូចជាៈ កាច់ដៃជើង ឆក់ខ្សែភ្លើង ឬយកស្បោងប្លាស្ទិកច្រកក្បាលរហូតដល់ស្ទើរដាច់ដង្ហើមស្លាប់ ។
- ការបំភិតបំភ័យ/គំរាមកំហែង
- ការដាក់ខ្នោះដៃ/ខ្នោះជើងរយៈពេលយូរ ។

វិធីដែលត្រូវបានរាយការណ៍ថា បានប្រើប្រាស់ប្រឆាំងនឹងអ្នកទោសដែលបានផ្តល់ចម្លើយបានបង្ហាញក្នុងតារាងទី១ ។[១០] តារាងនេះ រួមមានចម្លើយចម្រុះ អាស្រ័យដោយជនរងគ្រោះអាចឆ្លងកាត់ការធ្វើទារុណកម្មលើសពីមួយប្រភេទ ។ ករណីនៃការដាក់ខ្នោះជើង និងការបំភិតបំភ័យ ឬការគំរាមកំហែងដោយសម្តីដែលបានបង្ហាញនៅក្នុងតារាង គឺសុទ្ធតែមានការប្រើអំពើហិង្សាលើរាងកាយតាមរូបភាពណាមួយតាមក្រោយ ។




## ភាពធ្ងន់ធ្ងរនៃការធ្វើទារុណកម្ម

អ្នកផ្តល់ចម្លើយប្រមាណជា៧៩% អះអាងថាពួកគេបានសន្លប់ក្នុងអំឡុងពេលនៃការធ្វើទារុណ-កម្ម ហើយអ្នកផ្តល់ចម្លើយ ២១.៧% បានត្អូញត្អែរអំពីបញ្ហាសុខភាពរ៉ាំរ៉ៃដែលត្រូវការការព្យាបាល ។[១១]

[១០] អ្នកផ្តល់ចម្លើយចំនួន ២៩ នាក់ មិនត្រូវបានបញ្ចូលក្នុងតារាងនេះទេ អាស្រ័យដោយការពណ៌នាថា មានការធ្វើទារុណកម្មនោះមិនមានភាពគ្រប់គ្រាន់ ។

[១១] អាស្រ័យដោយពតិមាននេះ បានផ្តល់នូវសន្ទស្សន៍មួយពីភាពធ្ងន់ធ្ងរនៃការប្រើអំពើហិង្សា នោះសុខភាពពីមុនរបស់ជនរងគ្រោះក៏គួរតែត្រូវបានយកមកពិចារណាដែរ ។

អ្នកផ្ដល់ចម្លើយជាច្រើននាក់បានរាយការណ៍អំពីរបួសស្នាម ឬផលប៉ះពាល់ផ្នែកសុខភាពដទៃទៀតអំពីការធ្វើទារុណកម្ម ដែលក្នុងនោះរួមមានក្អកធ្លាក់ឈាម ហើម ឬចេញឈាមតាមផ្នែកផ្សេងៗនៃរាងកាយ ឈឺដើមទ្រូង ហើយក្នុងករណីខ្លះមានស្លាកស្នាមជាអចិន្ត្រៃយ៍ ។

ជាទូទៅ គេបានរាយការណ៍ថា មានប៉ូលីសលើសពីម្នាក់ដែលបានធ្វើទារុណកម្ម ។

ជាធម្មតា អ្នកផ្ដល់ចម្លើយបានរាយការណ៍អំពីការដាក់ខ្នោះដៃ ឬចង និងរុំមុខក្នុងពេលធ្វើទារុណកម្ម ។ ការប្រើវិធីដូចជាដាក់ខ្នោះដៃ គឺដើម្បីបង្ការកុំឱ្យជនរងគ្រោះព្យាយាមការពារខ្លួន ហើយការចងមុខធ្វើឱ្យពួកគេកាន់តែមានការភ័យខ្លាច និងកាន់តែពិបាកចំណាំភិនភាគអ្នកប្រព្រឹត្តបទល្មើស ។

ឧទាហរណ៍មួយអំពីករណីនៃការធ្វើទារុណកម្មធ្ងន់ធ្ងរ:

> ជនសង្ស័យម្នាក់ដែលត្រូវគេបញ្ជូនទៅស្នងការប៉ូលីសមួយនៅខេត្តស្វាយរៀងកាលពីឆ្នាំ២០០២ ត្រូវគេដាក់ខ្នោះដៃនៅពេលទៅដល់ ហើយត្រូវគេបញ្ជាឱ្យអង្គុយនៅលើឥដ្ឋ ។ ប៉ូលីស៣នាក់នាំគ្នាទាត់គាត់រហូតដល់សន្លប់ ។ នៅពេលដែលគាត់ដឹងខ្លួនឡើងវិញ ប៉ូលីសបានវាយបាតជើងរបស់គាត់ដោយដំបងឈើមួយ ហើយទាត់គាត់ចំខ្នងប្រហែល ៥ដង ដើម្បីបង្ខំឱ្យគាត់សារភាព ។ នៅយប់នោះ គាត់ត្រូវរងនូវការធ្វើទារុណកម្មម្ដងទៀត ។ ប៉ូលីសបានដាក់ខ្នោះដៃ ហើយយកក្រណាត់រុំមុខគាត់ ។ ប៉ូលីសបានទាត់គាត់ចំដើមទ្រូងចំនួនដប់ដង រួចគំរាមបាញ់គាត់ប្រសិនបើគាត់មិនសារភាព ។ បុរសនោះ បានសារភាពថាខ្លួនបានប្រព្រឹត្តអំពើប្លន់មែន ។ ប៉ុន្តែ ក្រោយមកគាត់បានប្រាប់អង្គការលីកាដូ ថាគាត់បានសារភាពពីព្រោះគាត់ខ្លាចប៉ូលីសធ្វើទារុណកម្មមកលើរូបគាត់រហូតដល់ស្លាប់ ។

**ករណីនៃការវាយទាត់ធាក់**

អ្នកផ្ដល់ចម្លើយភាគច្រើន ដែលមានចំនួនរហូតដល់ ៨១% បានរាយការណ៍ថាខ្លួនត្រូវបានប៉ូលីសវាយទាត់ធាក់ក្នុងអំឡុងពេលសួរចម្លើយ ។ ជាធម្មតា ជនរងគ្រោះរៀបរាប់អំពីការវាយធ្វើបាបធ្ងន់ធ្ងរ គឺមិនមែនគ្រាន់តែត្រូវគេទះកំភ្លៀងមួយដៃឬពីរដៃនោះឡើយ ។ ការរំលោភដែលត្រូវបានរាយការណ៍ជាទូទៅនោះ រួមមានការទាត់ចំមុខ ដើមទ្រូង ឬពោះ ឬចំឆ្អឹងជំនីរ ហើយនិងការចាប់ក្របួចសក់ក្បាលទះកំផ្លៀង ។ អំពើហិង្សានេះ ជាធម្មតា ត្រូវគេធ្វើឡើងនៅពេលដែលប៉ូលីសប៉ុនប៉ងបង្ខំយកចម្លើយសារភាព ឬពត៌មានអំពីបទល្មើសដែលគេចោទប្រកាន់មកលើជនរងគ្រោះ ។ ខាងក្រោមនេះជាឧទាហរណ៍មួយអំពីបុរសម្នាក់ដែលត្រូវប៉ូលីសឃុំឃាំងនៅឆ្នាំ២០០២ បានអះអាងថា:

> នៅពាក់កណ្ដាលអាធ្រាត ប៉ូលីសម្នាក់បានវាយខ្ញុំក្នុងពេលសួរចម្លើយ ហើយចោទខ្ញុំពីបទប្លន់ ។ នៅពេលដែលខ្ញុំបដិសេធ គេបានយកកែងដៃអុកខ្ញុំលើឆ្អឹងខ្នងប្រាំ-ប្រាំមួយដង ធ្វើឱ្យខ្ញុំឈឺចាប់យ៉ាងខ្លាំង ហើយគេបានទាត់ខ្ញុំពេញទំហឹងចំដើមទ្រូងបីដងធ្វើឱ្យខ្ញុំរឹតតែឈឺចាប់កាន់តែខ្លាំង ។ ខ្ញុំស្រែកអត់រួច ហើយក៏សន្លប់បាត់ស្មារតី ។ នៅម៉ោងទៀប៤ភ្លឺ ប៉ូលីសនោះបានមកសួរចម្លើយខ្ញុំ ហើយវ៉ៃខ្ញុំម្ដងទៀត ។ គេយកកែងដៃអុកឆ្អឹងខ្នងខ្ញុំបីដងយ៉ាងខ្លាំងៗ ។

នៅអំឡុងពេលសម្ភាសន៍ប៉ុន្មានសប្ដាហ៍ក្រោយអំពីការរំលោភបំពាន ដែលគេចោទប្រកាន់នោះ បុរសនោះនៅតែត្អូញត្អែរថាគាត់នៅមិនទាន់បាត់ឈឺនៅឡើយ ។

បុរសម្នាក់ទៀតដែលត្រូវគេចាប់នៅខេត្តកំពង់ឆ្នាំង បានរៀបរាប់ថាៈ

> នៅក្នុងបន្ទប់ឃុំឃាំង គេយកច្រវ៉ាក់ដែកវាយចំដើមទ្រូង និងខ្នង ហើយខ្ញុំរងរបួសយ៉ាងធ្ងន់ធ្ងរ ។ បន្ទាប់មកប៉ូលីសម្នាក់ទៀតដែលស្លៀកពាក់ឯកសណ្ឋានបានចូលទៅក្នុងបន្ទប់ឃុំឃាំង រួចបានចាប់ក្របួចសក់ខ្ញុំហើយបោកក្បាលខ្ញុំផ្ទប់ទៅនឹងទ្វារ ។ គេទាត់ខ្ញុំចំខ្នង នៅពេលគេទាត់ខ្ញុំ ហើយប៉ូលីសម្នាក់ទៀតយកដំបងឆក់វាយជើងនិងក្បាលពោះខ្ញុំ។ ខ្ញុំដួលទៅដី ខ្ញុំមានការឈឺចាប់យ៉ាងខ្លាំង។ នៅថ្ងៃបន្ទាប់ ប៉ូលីសបីនាក់ដដែល ដែលបានធ្វើទារុណកម្មខ្ញុំនៅថ្ងៃមុនបានយកខ្ញុំទៅបន្ទប់ឃុំឃាំង ដើម្បីសួរចម្លើយម្តងទៀត ។ ប៉ូលីសម្នាក់បានប្រើច្រវ៉ាក់ដែកវាយខ្នង និងគូថរបស់ខ្ញុំ ហើយម្នាក់ទៀតទាត់ខ្ញុំចំក្បាលពោះ ចង្កេះ ខ្នង និងកញ្ចឹងក។ ខ្ញុំក៏ដួលទៅលើដី។ ពួកគេក៏បញ្ជាខ្ញុំឱ្យក្រោកឈរ ហើយពេលដែលខ្ញុំក្រោកឈរ ពួកគេទាំងអស់នាំគ្នាវាយទាត់ធាក់ខ្ញុំទៀត រហូតដល់ខ្ញុំសន្លប់បាត់ស្មារតី ។

បុរសនេះមានស្នាមរបួសជាអចិន្ត្រៃយ៍ ហើយនៅពេលសម្ភាសន៍ គាត់នៅតែត្អូញត្អែថានៅមានការឈឺចាប់នៅឡើយ ។

### ការវាយដោយប្រើឧបករណ៍

អ្នកទោសចំនួន ៤៩% ដែលបានរាយការណ៍អំពីការធ្វើទុក្ខបុកម្នេញពីប៉ូលីស បាននិយាយថា ពួកគេត្រូវបានប៉ូលីសវាយដោយឧបករណ៍ប្រភេទណាមួយ ជាទូទៅដោយស្វាយកាំភ្លើង ដំបងឈើឬឬស្សី ដំបងឆក់ ខ្សែក្រវ៉ាត់ បំពង់ទីប ដំបងដែក ច្រវ៉ាក់ ឬខ្សែពួរ ។

> **ឧទាហរណ៍អំពីការវាយដោយឧបករណ៍**
>
> បុរសម្នាក់ត្រូវគេចាប់ខ្លួនពីបទចោរកម្ម ហើយត្រូវគេឃុំឃាំងនៅកន្លែងឃុំឃាំងប៉ូលីសខេត្តស្វាយរៀង នៅឆ្នាំ ២០០២ ។ នៅពេលដែលគាត់ទៅដល់ទីនោះ ប៉ូលីសពីរនាក់បានបង្ខំឱ្យគាត់ដោះខោអាវចេញ ។ នៅពេលដែលគាត់ស្រាតខោអាវហើយ គេយកខោរបស់គាត់មកចងដៃគាត់។ ប៉ូលីសម្នាក់បានវាយដើមទ្រូងជនជាប់សង្ស័យរូបនេះដោយដំបងជ័រ ហើយបង្ខំឱ្យគាត់សារភាពថា បានលួចរថយន្តមួយគ្រឿង។ ជនជាប់សង្ស័យបានបដិសេធ ហើយប៉ូលីសបានវាយខ្នង និងដើមទ្រូងរបស់គាត់ដោយដំបងឈើមួយ ។ នៅពេលដែលជនរងគ្រោះនៅតែបដិសេធមិនព្រមសារភាព ប៉ូលីសបានបន្តវាយគាត់ខ្លាំងឡើងៗដោយដំបងនោះ ។ នៅពេលដែលជនជាប់សង្ស័យក្អកធ្លាក់ឈាម ទើបប៉ូលីសឈប់វាយ ។ នៅពេលដែលអង្គការលីកាដូ បានសម្ភាសន៍គាត់នៅក្នុងពន្ធនាគារ ជនរងគ្រោះបានត្អូញត្អែរថាគាត់នៅឈឺមួយចំហៀងខ្លួន ហើយគាត់ប្រាប់ថា គាត់ដេកមិនលក់ ។

## រូបភាពផ្សេងទៀតនៃការធ្វើទារុណកម្ម

អ្នកផ្តល់ចម្លើយចំនួន ១៥% បានរាយការណ៍អំពីវិធីធ្វើទារុណកម្មផ្សេងៗទៀត ក្នុងនោះរួមមាន

## រូបភាពផ្សេងៗទៀតនៃការធ្វើទារុណកម្ម

អ្នកផ្តល់ចំលើយចំនួន ១៥% បានរាយការណ៍ពីរូបភាពផ្សេងៗនៃការធ្វើទារុណកម្ម រួមមានឆក់ខ្សែភ្លើង យកស្បោងច្រកក្បាលរហូតថប់ដង្ហើមស្ទើរស្លាប់ ចាប់ជ្រមុជទឹក និងយកកន្ទុយបារីដុត ។ មានរបាយការណ៍ខ្លះទៀតអំពីការកាច់អាវៈយវៈ ដែលអ្នកសួរចម្លើយដាក់ខ្នោះជើង ហើយឡើងជាន់ជើងពួគេយ៉ាងយូរ ឬក៏ពាក់ស្បែកជើងប៊ូឡើងជាន់ផ្នែកផ្សេងៗនៃរាងកាយរបស់គេ។ វិធីបែបនេះកើតមានជាទូទៅនៅខេត្តកំពង់ធំ និងបន្ទាយមានជ័យ។ មានករណីពីរដែលរាយការណ៍អំពីការយកដែកគោលរុកត្រចៀកជនរងគ្រោះ នៅក្រុងកំពង់សោម។ អ្នកទោសម្នាក់បានពន្យល់ថាៈ

> នៅពេលដែលខ្ញុំបានមកដល់(កន្លែងឃុំឃាំងប៉ូលីស) ប៉ូលីសបីនាក់បានធ្វើទារុណកម្មខ្ញុំ ។ ពួកគេបានទាត់ធាក់ខ្ញុំជាច្រើនដងចំខ្នង ហើយគេដាល់ដើមទ្រូងខ្ញុំយ៉ាងខ្លាំង។ បន្ទាប់មក ប៉ូលីសម្នាក់បានយកស្បោងកៅស៊ូមកច្រកក្បាលខ្ញុំ ហើយគេបានទះផ្ទប់ត្រចៀកខ្ញុំ ។ ពួកគេធ្វើទារុណកម្មខ្ញុំរហូតដល់ខ្ញុំសន្លប់ ។ នៅពេលដែលខ្ញុំដឹងខ្លួនឡើងវិញ ប៉ូលីសបានយកដែកគោលរុកត្រចៀកខ្ញុំរហូតដល់ចេញឈាម។

នៅពេលលីកាដូសម្ភាសន៍គាត់នៅក្នុងពន្ធនាគារ បុរសនោះបានត្អូញត្អែរថាឈឺដើមទ្រូង ហើយក្អកធ្លាក់ឈាម ។

## ការគំរាមកំហែង និងបំភិតបំភ័យដោយពាក្យសម្តី

ការគំរាមកំហែង និងបំភិតបំភ័យដោយសម្តី ត្រូវបានរៀបរាប់ដោយអ្នកទោស ២៦% ក្នុងចំណោមអ្នកទោស ២៨១ នាក់ ដែលត្រូវបានគេធ្វើទុក្ខបុកម្នេញ ។ នៅក្នុងករណីទាំងអស់ ការបំភិតបំភ័យបានកើតឡើងដោយអំពើហិង្សាលើរាងកាយ ។ រាល់អំពើទារុណកម្ម ឬការធ្វើទុក្ខបុកម្នេញទាំងអស់គឺជារូបភាពនៃការបំភិតបំភ័យដោយចេតនា ដែលបណ្តាលឱ្យជនរងគ្រោះមានការភ័យខ្លាច ប៉ុន្តែប្រភេទនៃការធ្វើទុក្ខបុកម្នេញបែបនេះ សំដៅទៅលើអ្នកផ្តល់ចម្លើយដែលបានពណ៌នាជាក់ស្តែងអំពីការគំរាមកំហែង ឬការបំភិតបំភ័យជាក់ស្តែងដោយប៉ូលីស ។ ការបំភិតបំភ័យដែលបានរាយការណ៍ រួមមានការគំរាមបាញ់ ឬវាយជនរងគ្រោះដល់ស្លាប់ ប្រសិនបើមិនសារភាព ការដាក់កាំភ្លើងនៅលើតុពីមុខជនរងគ្រោះក្នុងអំឡុងពេលសួរចម្លើយ ការគំរាមប្រគល់ជនរងគ្រោះទៅឱ្យហ្វូងមនុស្សវាយដល់ស្លាប់ និងការគំរាមបញ្ជូនជនរងគ្រោះទៅពន្ធនាគារប្រសិនបើគេមិនឆ្លើយសំណួរអោយបាន "ត្រឹមត្រូវ" ទេ។

ករណីមួយនៅក្នុងខេត្តកំពង់ធំ គេបានចោទប្រកាន់ថាតម្រួតយោធាបានគំរាមរំលោភអ្នកទោសស្ត្រីប្រាំនាក់។

អាត្រាដ៏ខ្ពស់នៃការគំរាមកំហែង និងការបំភិតបំភ័យ ត្រូវបានរាយការណ៍ដោយឡែកនៅខេត្តកំពង់ឆ្នាំង កំពង់ធំ កោះកុង និងកំពង់ចាម ប៉ុន្តែវាក៏កើតមានជាទូទៅនៅទូទាំងប្រទេសផងដែរ។

### ករណីនៃការដាក់ខ្នោះជើង ឬខ្នោះដៃ

ការដាក់ខ្នោះជើង ឬខ្នោះដៃរយៈពេលយូរ អាចមុតចូលក្នុងសាច់ធ្វើឱ្យស្ទះចរន្តឈាម ហើយរារាំងមិនអោយធ្វើចលនា ដែលបណ្តាលឱ្យមានការឈឺចាប់ធ្ងន់ធ្ងរ និងពិការភាពជាអចិន្ត្រៃយ៍ផងដែរ។ អ្នកផ្តល់ចម្លើយចំនួន ១០% បានអះអាងថាខ្លួនត្រូវគេដាក់ខ្នោះជើង ឬខ្នោះដៃមួយយប់នៅពេលជាប់ឃុំ។ អ្នកទោសចំនួនពាក់កណ្តាល ដែលត្រូវបានសម្ភាសន៍នៅខេត្តកំពង់ចាម បានរាយការណ៍អំពីការដាក់ខ្នោះជើងនៅកន្លែងឃុំឃាំងរបស់ប៉ូលីស បន្ទាប់ពីការចាប់ខ្លួន។

## អ្នកប្រព្រឹត្តបទល្មើស និងកន្លែងធ្វើទារុណកម្ម

អ្នកទោសចំនួន ៨១,៥% ក្នុងចំណោមអ្នកទោស ២៨១ នាក់ បានរៀបរាប់ថាការធ្វើទារុណកម្មបានកើតឡើងបន្ទាប់ពីការចាប់ខ្លួនក្នុងអំឡុងពេលដែលត្រូវខ្លួនគេឃុំឃាំងនៅក្នុងស្ថានីយ៍ប៉ូលីសឬស្ថាប័នដទៃទៀត ។ អ្នកទោសជិត ១២% បាននិយាយថាខ្លួនត្រូវគេធ្វើទុក្ខបុកម្នេញទាំងនៅក្នុងអំឡុងពេលចាប់ខ្លួន និងនៅស្ថានីយ៍ប៉ូលសីស។

**ឧទាហរណ៍នៃការធ្វើទារុណកម្មក្នុងកំឡុងពេលចាប់ខ្លួន**

បុរសម្នាក់នៅខេត្តសៀមរាប ត្រូវបានចាប់ខ្លួននៅផ្ទះរបស់គាត់ដោយប៉ូលីសមួយក្រុម នៅឆ្នាំ២០០១។ ប៉ូលីសបានបាញ់កាំភ្លើងប្រឡោះជើង ដើម្បីគំរាមគាត់។ ពួកគេបានចងគាត់ជាប់សរសរ ហើយព្យាយាមបាញ់កាំភ្លើងក្បែរគុម្ពត្រចៀក ប៉ុន្តែកាំភ្លើងបាញ់មិនចេញ។ នៅត្រង់ចំណុចនេះ ប៉ូលីសម្នាក់បាននិយាយថាបុរសនោះប្រាកដជាចេះមន្តអាគម ហើយយកស្មាយកាំភ្លើងវាយគាត់រហូតដល់សន្លប់។ បន្ទាប់ពីបុរសនោះដឹងខ្លួន គាត់ត្រូវគេបណ្តើរទៅប៉ុស្តិ៍ប៉ូលីស ហើយប៉ូលីសបានទាត់វាយ និងគំរាមបាញ់គាត់តាមផ្លូវ។ គាត់មានរបួសក្បាលយ៉ាងធ្ងន់ធ្ងរនៅពេលដែលគាត់មកដល់ប៉ុស្តិ៍ប៉ូលីស។

ក្នុងអំឡុងពេលប៉ូលីសចាប់ខ្លួន អ្នកផ្តល់ចម្លើយចំនួន ៧,៤% បានអះអាងថាពួកគេត្រូវប្រជាជនវាយធ្វើបាប ។ មិនមានពតិមានពិតប្រាកដថាតើប៉ូលីសខាងចាប់ចងបានព្យាយាមរារាំងកុំឱ្យមានអំពើហិង្សាបែបនេះ ឬក៏អត់នោះទេ ប៉ុន្តែតួលេខនេះពិតជាបានបង្ហាញនូវកម្រិតនៃការមិនខ្វល់ខ្វាយរបស់ប៉ូលីសចំពោះអំពើហិង្សារបស់មហាជនមកលើជនសង្ស័យថាបានប្រព្រឹត្តបទល្មើស។

ទីកន្លែងដែលបានរាយការណ៍អំពីការឃុំឃាំង និងធ្វើទុក្ខបុកម្នេញដើមដំបូងត្រូវបានបង្ហាញនៅក្នុងតារាងទី២។ អ្នកផ្តល់ចម្លើយភាគច្រើន ដែលមានចំនួន ៥៣%ត្រូវបានគេឃុំឃាំង និងធ្វើទុក្ខបុកម្នេញដើមជាដំបូងនៅអធិការដ្ឋាននគរបាលស្រុក ១៥% ត្រូវបានឃុំឃាំងដោយកងរាជអាវុធហត្ថ ហើយ ១៣% ត្រូវបានឃុំឃាំងនៅស្នងការដ្ឋាននគរបាលខេត្ត។

អ្នកផ្តល់ចម្លើយចំនួន ៧%ទៀតត្រូវបានគេឃុំឃាំងនៅក្នុងប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ ហើយ ២% ត្រូវគេឃុំឃាំងនៅកន្លែងផ្សេងៗ ដូចជាបន្ទាយយោធា ឬដោយភ្នាក់ងារសន្តិសុខ។

ករណីនៃការធ្វើទារុណជាច្រើន ដែលបានរាយការណ៍នៅក្នុងខេត្តកពង់ធំ បាត់ដំបង និងជាពិសេសនោះ គឺខេត្តបន្ទាយមានជ័យបានកើតឡើងនៅក្រោមការឃុំឃាំងរបស់កងរាជអាវុធហត្ថ ។ នៅខែ មករា ឆ្នាំ២០០២ អំណាចរបស់កងរាជអាវុធហត្ថនៅទូទាំងប្រទេសក្នុងការចាប់ចង និងឃុំឃាំងជនសង្ស័យជាជនស៊ីវិលត្រូវបានកាត់បន្ថយ ប៉ុន្តែច្បាប់ដូចជាមិនច្បាស់ ហើយជាញឹកញាប់ពួកគេនៅតែបន្តអនុវត្តអំណាចនេះ។




មានករណីចំនួនបួន ដែលត្រូវបានរាយការណ៍អំពីការឃុំឃាំង និងធ្វើទុក្ខបុកម្នេញទៅលើជនជាប់សង្ស័យជាជនស៊ីវិលនៅបន្ទាយយោធា ទោះបីជាយោធាមិនមានអំណាចស្របច្បាប់ ដើម្បីចាប់ចងជនស៊ីវិលក្តី។

**ឧទាហរណ៍នៃការធ្វើទារុណកម្មដោយយោធាទៅលើជនស៊ីវិល**

នៅឆ្នាំ២០០១ នាយទាហានពីរនាក់ដែលកំពុងហូបបាយនៅភោជនីយដ្ឋានមួយនៅខេត្តកំពង់ស្ពឺ មានជម្លោះជាមួយបុរសបីនាក់ដែលយកដប និងកែវវាយពួកគេ។ បុរសទាំងបីនាក់នោះបានរត់គេចខ្លួន។ នៅម៉ោង ១១យប់ ទាហាន ១០ នាក់ មកពីមជ្ឈមណ្ឌលហ្វឹកហ្វឺនយោធាមួយបានព័ទ្ធចាប់បុរសទាំងបីនាក់នៅខ្ទមមួយ។ ក្នុងអំឡុងពេលចាប់ខ្លួនបុរសម្នាក់ក្នុងចំណោមបុរសទាំងបីត្រូវគេទាត់១០ទៅ២០ជើង ហើយវាយនឹងដំបងដែក ១០ ទៅ ១៥ ដំបង។ ពួកទាហានក៏បានវាយបុរសនោះដោយដំបងឈើ រហូតដល់បាក់ជាពីរ ហើយយកពូថៅកាប់ដៃរបស់គាត់។ នៅចំណុចមួយ បុរសនោះត្រូវគេវាយជាច្រើនដង ដោយដំបងដែក។ បន្ទាប់ពីវាយហើយ ពួកទាហានបានឃុំឃាំង និងដាក់ខ្នោះជើងបុរសនោះនៅមជ្ឈមណ្ឌលហ្វឹកហ្វឺនយោធា ។ ក្រោយមកគេបានបញ្ជូនបុរសនោះទៅអោយប៉ូលីស រួចយកទៅដាក់ពន្ធនាគារ។ ជាលទ្ធផលនៃរបួសដៃ និងក្បាលបុរសនោះមានបញ្ហាសុខភាពរ៉ាំរ៉ៃ។

ក្នុងខណៈដែលតួលេខខាងលើសំដៅទៅលើកន្លែងឃុំឃាំងដើមដំបូង គេបានរកឃើញថា ជនរងគ្រោះប្រហែលជាមួយភាគបួនត្រូវបានគេឃុំឃាំងលើសពីមួយកន្លែង ។ ជាទូទៅមនុស្សដែលត្រូវគេចាប់ខ្លួនត្រូវគេបញ្ជូនពីថ្នាក់ឃុំទៅថ្នាក់ស្រុក ឬពីថ្នាក់ស្រុកដល់ថ្នាក់ខេត្ត ។ នៅក្នុងករណីខ្លះជនរងគ្រោះត្រូវធ្វើទារុណកម្មនៅស្ថានីយ៍ប៉ូលីសលើសពីមួយកន្លែង។

## ការស្លាប់នៅក្នុងកន្លែងឃុំឃាំងរបស់ប៉ូលីស

វាមានការពិបាកក្នុងការកំណត់ចំនួនមនុស្សដែលស្លាប់ដោយស្នាដៃប៉ូលីស ក្នុងកំឡុងពេលឃុំឃាំង។ ជាធម្មតាប៉ូលីសបានបិទបាំងនូវបទឧក្រិដ្ឋរបស់គេ ។ ការស៊ើបអង្កេតឱ្យបានល្អិតល្អន់បានធ្វើឡើងដោយកម្រ ហើយសាក្សីមានការញញើតញញើមមិនហ៊ាននិយាយ ។

ខាងក្រោមនេះ គឺជាការស្លាប់មួយនៅក្នុងកន្លែងឃុំឃាំងរបស់ប៉ូលីសដែលត្រូវបានរាយការណ៍នៅឆ្នាំ ២០០១។

អៀក អឿន ដែលត្រូវគេចោទថាជាចោរលួចក្របីនោះ ត្រូវបានគេចាប់ខ្លួននៅស្រុកបាភ្នំក្នុងខេត្តព្រៃវែង កាលពីថ្ងៃទី ២៦ កក្កដា ឆ្នាំ២០០១ ហើយបានស្លាប់បីថ្ងៃក្រោយមកពីរបួសដែលគេចោទថាបណ្តាលមកពីការធ្វើទារុណកម្ម។ នៅមុនពេលគាត់ស្លាប់ គាត់បានប្រាប់សាក្សីអំពីឈ្មោះប៉ូលីសបីនាក់ដែលគាត់ចោទថា បានធ្វើទារុណកម្មមកលើរូបគាត់។

លីកាដូ បានបញ្ជូនរូបថតសាកសពរបស់ អៀត អឿន ដែលបង្ហាញនូវស្នាមរបួសនិងស្នាមជាំជាច្រើនព្រមជាមួយនឹងការរៀបរាប់របស់សាក្សី ទៅឱ្យអ្នកជំនាញខាងកោសល្យវិច្ច័យពិនិត្យរោគសាស្ត្រ នៅឯសាកល

វិទ្យាល័យហ្វីលីពីននៅក្រុងម៉ានីល ដែលបានធ្វើការសន្និដ្ឋានថា: "ផ្អែកលើពតិមានដែលមានទាក់ទងទៅនឹងកាលៈទេសៈនៃការស្លាប់របស់គាត់ ស្នាមរបួសក្បាលត្រូវបានចាត់ទុកយ៉ាងរឹងមាំថា ជាដើមហេតុផ្ទាល់ ហើយព្រោះហេតុដូច្នេះលក្ខណៈនៃការស្លាប់ត្រូវចាត់ទៅក្នុងប្រភេទនៃមនុស្សឃាត ។"

ដោយមានសម្ពាធពីក្រុមសិទ្ធិមនុស្សក្នុងស្រុក និងអន្តរជាតិ តុលាការព្រៃវែងបានដាក់ការចោទប្រកាន់ទៅលើប៉ូលីសពីនាក់ពីបទមនុស្សឃាតដោយស្ម័គ្រចិត្ត នៅខែ កុម្ភៈ ឆ្នាំ២០០២ គឺបន្ទាប់ពី អៀត អឿន បានស្លាប់ជាងប្រាំមួយខែមក។ ប៉ូលីសទីបីត្រូវបានតុលាការធ្វើការចោទប្រកាន់ នៅខែ កក្កដា ឆ្នាំ ២០០២។ ក្នុងអំឡុងពេលនៃការសរសេររបាយការណ៍នេះ សំណុំរឿងនេះកំពុងត្រៀមយកមកជំនុំជំរះ។ ការកាត់ទោសប៉ូលីសពីបទចោទប្រកាន់ទាក់ទងនឹងការធ្វើទារុណកម្មបែបនេះកើតមានដោយកម្របំផុត។

## មូលហេតុនៃការធ្វើទារុណកម្ម នៅក្នុងកន្លែងឃុំឃាំងរបស់ប៉ូលីស

ហេតុអ្វីបានជាមនុស្សត្រូវគេធ្វើទុក្ខបុកម្នេញនៅក្នុងកន្លែងឃុំឃាំងរបស់ប៉ូលីសជាប្រក្រតី និងជាទម្លាប់នោះ? វិធីនៃការធ្វើទារុណកម្មនៅពេលបច្ចុប្បន្ន និងគោលបំណងរបស់វានៅតែដូចគ្នានឹងបច្ចេកទេស ដែលគេបានប្រើប្រាស់កាលពីអតីតកាលក្នុងប្រទេសកម្ពុជា។ ការធ្វើទារុណកម្មលើរាងកាយ និងផ្លូវចិត្តត្រូវគេអនុវត្តគ្រប់ប្រវត្តិសាស្ត្រកម្ពុជាក្នុងគោលបំណងដើម្បី:

- បង្ខំយកចម្លើយសារភាព ឬពតិមានដទៃទៀត
- ដាក់ទណ្ឌកម្មទៅលើមនុស្សដែលគេយល់ថាបានប្រព្រឹត្តខុស
- ជម្រិតយកប្រាក់ពីអ្នកជាប់ទោស។

ទាំងនេះនៅតែជាគោលបំណងសំខាន់នៃការធ្វើទារុណកម្មដោយប៉ូលីស នៅពេលបច្ចុប្បន្ននេះ។ ទោះបីជាយ៉ាងណា កត្តាទាំងនេះមិនអាចដំណើរការតែឯងដោយជោគជ័យនោះឡើយ ។ មានធាតុដទៃទៀតដែលគាំទ្របន្ថែមទៅលើបញ្ហានេះក្នុងនោះរួមមាន÷ នីតិវិធី និងជំនាញក្នុងការអនុវត្តច្បាប់ដែលមិនគ្រប់គ្រាន់ ជាពិសេស ការពឹងផ្អែកទៅលើចម្លើយសារភាពជាភស្តុតាងបឋមប្រឆាំងនឹងជនជាប់សង្ស័យថាជាជនល្មើស ការឃុំឃាំងអោយនៅឯកោដោយប៉ូលីស និងកង្វះខាតនៃការត្រួតពិនិត្យពីខាងក្រៅទៅលើឥរិយាបថរបស់ប៉ូលីសតុលាការមិនបានប្រឆាំងនឹងការធ្វើទារុណកម្ម ហើយនិងឥរិយាបថសង្គមចំពោះជនសង្ស័យថាជាជនល្មើស។

ការធ្វើទារុណកម្ម ក៏ត្រូវបានបង្កដោយសញ្ញាណនៃអំណាចដែលមានតាំងពីយូរយាមកដោយឋានានុក្រម និងបរិបាលកិច្ចដែលផ្អែកលើគោលការណ៍ដែលថា មនុស្សដែលមិនសូវមានអំណាចត្រូវដាក់ខ្លួនចំពោះអំណាចរបស់មនុស្សដែលមានអំណាចជាងខ្លួន ។ ជាផលវិបាកនៃប្រព័ន្ធនេះវាបណ្តាលឱ្យមាននូវកង្វះខាតនៃការទទួលខុសត្រូវរបស់ជនល្មើសដែលមានអំណាច និងមានឥទ្ធិពលនៅចំពោះមុខច្បាប់ ។

ប្រការដែលថាការធ្វើទារុណកម្មត្រូវបានប្រើប្រាស់ដោយមនុស្សដែលស្ថិតក្នុងតួនាទី ដែលមានអំណាច ហើយដែលអ្នកទាំងនោះគួរតែជាអ្នកការពារសង្គម និងសិទ្ធិរបស់ប្រជាពលរដ្ឋនោះបានបង្ហាញនូវការកើតមានជាថ្មីនូវឥរិយាបថចាស់ចំពោះអំណាច។ សរុបមកការធ្វើទារុណកម្មរបស់ប៉ូលីសកើនឡើងពីព្រោះតែគេបានទទួលយក និងអនុញ្ញាតឱ្យគេធ្វើដូច្នេះ។

### *មូលហេតុជាបឋមនៃការធ្វើទារុណកម្ម:*

### ប៉ូលីសប្រើប្រាស់ការធ្វើទារុណកម្ម ដើម្បីបង្ខំយកចម្លើយសារភាព

ការធ្វើទារុណកម្ម ដើម្បីបង្ខំយកចម្លើយសារភាពត្រូវបានប៉ូលីសប្រើប្រាស់ដូចគ្នា។ អស់រយៈពេលដ៏យូរមកហើយ ប៉ូលីសបានពឹងផ្អែកទៅលើការបង្ខំយកចម្លើយសារភាពពីជនជាប់ចោទពីបទល្មើសដែលត្រូវគេចាត់ទុកថាជាផ្នែកសំខាន់បំផុតនៃការស៊ើបអង្កេតក្នុងរឿងព្រហ្មទណ្ឌមួយ ។ ប្រការនេះ វាបានបណ្តោយឱ្យកើតឡើងដោយតុលាការជាទូទៅស្ម័គ្រចិត្តទទួលយកនូវចម្លើយសារភាពដោយបង្ខំ ដែលជាភស្តុតាងនៃពិរុទ្ធភាពរបស់ជនជាប់ចោទ ហើយនិងកង្វះខាតនូវឆន្ទៈអំពីអាជ្ញាធរថ្នាក់លើក្នុងការរារាំងនូវការប្រព្រឹត្តបែបនេះ។ ដូចដែលបានរៀបរាប់មកខាងលើ អ្នកជាប់ពន្ធនាគារចំនួន ៩០% បាននិយាយថាពួកគេបានឆ្លើយសារភាពក្នុងអំឡុងពេលសួរចម្លើយ។ ឧទាហរណ៍ បុរសម្នាក់ដែលត្រូវគេឃុំឃាំងនៅខេត្តកោះកុង បានព្យល់ដូចខាងក្រោម ÷

> ពួកគេបានសួរខ្ញុំថា:"ហ្អែងមានចាប់ជម្រិតគេទេ ហើយហ្អែងលាក់លុយនៅឯណា?" ខ្ញុំបានប្រាប់ពួកគេថាខ្ញុំមិនដឹងរឿងអ្វីអំពីការចាប់ជម្រិតនោះទេ។ ប៉ុន្តែខ្ញុំមិនទាន់និយាយចប់ផង ពួកគេទាត់ខ្ញុំបួនដើងចំដើមទ្រូង យកដំបងជ័រវាយកញ្ជើងក និងភ្លៅខ្ញុំបីដំបង ហើយគំរាមបាញ់ខ្ញុំ។ ប៉ូលីសម្នាក់បាននិយាយថា: "បើហ្អែងមិនព្រមនិយាយថាហ្អែងបានចាប់ជម្រិតទេ អញនឹងបាញ់ហ្អែង និងកូនហ្អែង!" ពេលខ្ញុំឮអីចឹង ខ្ញុំខ្លាចណាស់ ហើយនិយាយថា:"ខ្ញុំអត់ដឹងរឿងចាប់ជម្រិតនោះមែន ។ ទោះបីជាបងឯងបាញ់ខ្ញុំ ក៏ខ្ញុំគ្មានពតិមានអីនិយាយប្រាប់ដែរ។" ពួកគេនៅស្ងៀមពីរ-បីនាទី ហើយបន្តសួរខ្ញុំទៀត ។ ពួកគេបន្តធ្វើទារុណកម្មខ្ញុំទៀត។ ចុងក្រោយខ្ញុំទ្រាំលែងបាន ហើយខ្ញុំក៏ឆ្លើយតាមតែគេចង់បាន។

នៅខេត្តព្រៃវែង ក្មេងប្រុសអាយុ១៨ឆ្នាំម្នាក់ដែលត្រូវគេចោទថាបានលួចគោនោះ បានបញ្ជាក់ប្រាប់ថា ÷

> ខ្ញុំត្រូវគេយកទៅកន្លែងប៉ូលីស ហើយគេបញ្ជាឱ្យខ្ញុំលុតជង្គង់ រួចឱ្យសារភាពថា ខ្ញុំបានចូលដៃជាមួយចោរផ្សេងទៀត។ ខ្ញុំបានបដិសេធ ហើយគេវៃខ្ញុំពីរព្រនង់ចំក្បាល និងមួយព្រនង់ចំខ្នង។ បន្ទាប់មកប៉ូលីសចូលមកហើយទាត់ខ្ញុំពីរជើង រួចបង្ខំខ្ញុំឱ្យផ្តិតមេដៃសារភាពលើកំណត់ហេតុសួរចំលើយ (ចំលើយសារភាព)។

យើងមិនអាចដឹងឱ្យប្រាកដថា តើមានជនសង្ស័យពីបទព្រហ្មទណ្ឌប៉ុន្មាននាក់ ដែលត្រូវគេកាត់ទោសឱ្យជាប់ពន្ធនាគារ ដោយផ្អែកលើចម្លើយសារភាពដោយការធ្វើទារុណកម្មនោះឡើយ ។[១២] ទោះបីជាយ៉ាងណាព្រះរាជអាជ្ញាម្នាក់នៅក្រុងកំពង់សោមបានបញ្ជាក់ថា ចម្លើយសារភាពត្រូវបានគេភ្ជាប់មកជាមួយសំណុំរឿងព្រហ្មទណ្ឌភាគច្រើន ដែលប៉ូលីសបញ្ជូនមកតុលាការ ។ ប៉ូលីសសង្កត់ធ្ងន់ទៅលើការបង្ខំយកចម្លើយសារភាព ហើយប្រការនេះជាបឋមត្រូវបានចៅក្រម និងព្រះរាជអាជ្ញាទទួលយកចម្លើយសារភាពទាំងនេះនៅក្នុងតុលាការ ទោះបីជាវាជាចម្លើយសារភាពដោយបង្ខំ ឬមិនបង្ខំក៏ដោយ ។

## ប៉ូលីសប្រើប្រាស់ការធ្វើទារុណកម្ម ដើម្បីជម្រិតយកប្រាក់

នៅក្នុងបទសម្ភាសន៍របស់លីកាដូជាមួយនឹងអ្នកទោសចំនួន ២៨១ នាក់ ដែលបានអះអាងពីការធ្វើទុក្ខបុកម្នេញរបស់ប៉ូលីស មានអ្នកទោសចំនួន ១៤% បានលាតត្រដាងថា ប៉ូលីសបានទាមទារប្រាក់ពីពួកគេនៅក្នុងអំឡុងពេលឃុំឃាំង ។ តួលេខនេះគ្រាន់តែជាសន្ទស្សន៍មួយប៉ុណ្ណោះ ហើយវាមានការពិបាកក្នុងការស្ទង់មើលនូវទំហំពិតប្រាកដនៃការធ្វើទារុណកម្មរបស់ប៉ូលីសក្នុងគោលបំណងដើម្បីជម្រិតយកប្រាក់នោះ ។ អាស្រ័យដោយអំពើពុករលួយវាកើតឡើងជាទូទៅនៅក្នុងប្រទេសកម្ពុជានោះ អ្នកផ្តល់ការសម្ភាសន៍ប្រហែលជាមិនចាត់ទុកថាការជម្រិតយកប្រាក់ដោយប៉ូលីសជាពតិមានសំខាន់ ដែលត្រូវលាតត្រដាងនោះឡើយ ។ ដូចគ្នានេះដែរ បន្ថែមពីលើជនរងគ្រោះនៃការធ្វើទារុណកម្ម និងការជម្រិតយកប្រាក់ដែលចុងបញ្ចប់ត្រូវជាប់ពន្ធនាគារនោះ វាមិនប្រាកដថាតើមានមនុស្សប៉ុន្មាននាក់ ដែលអាចត្រូវប៉ូលីសចាប់ខ្លួន តែត្រូវដោះលែងមកវិញបន្ទាប់ពីត្រូវគេបង្ខំឱ្យបង់ប្រាក់រួចហើយនោះ ។

**ឧទាហរណ៍នៃការជម្រិតយកប្រាក់ និងការធ្វើទារុណកម្ម**

បុរសម្នាក់ដែលត្រូវគេចាប់ខ្លួន ហើយឃុំឃាំងនៅអធិការដ្ឋាននគរបាលខ័ណ្ឌមួយនៅភ្នំពេញកាលពីខែកញ្ញា ឆ្នាំ២០០២ បាននិយាយថា គាត់ត្រូវបានគេយកទៅដាក់ក្នុងបន្ទប់ងងឹតមួយដើម្បីសួរចំលើយ ។ នគរបាលម្នាក់បានចោទប្រកាន់គាត់អំពីអំពើប្លន់ ហើយបានសួរគាត់ថាៈ "ហ្អែងមានលុយទេ? បើហ្អែងចង់ឱ្យគេដោះលែងហ្អែងត្រូវបង់ ៥០០ ដុល្លាអាមេរិក ។" បុរសនោះបានប្រាប់ទៅប៉ូលីសថា គាត់មិនមែនជាចោរប្លន់ទេ ហើយថាគាត់គ្មានលុយឡើយ ។ ប៉ូលីសបានដាល់គាត់ចំមុខ ហើយទាត់ខ្លួនគាត់រហូតដល់ចុងក្រោយបុរសនោះក៏សារភាព ហើយត្រូវគេបញ្ជូនទៅតុលាការ ។

---

[១២] រដ្ឋធម្មនុញ្ញកម្ពុជា (មាត្រា ៣៨) និងច្បាប់ព្រហ្មទណ្ឌអន្តរកាល(មាត្រា ២៤.៣) បានហាមឃាត់មិនឱ្យប្រើប្រាស់ការបង្ខំយកចម្លើយសារភាពធ្វើជាភស្តុតាងនៅក្នុងតុលាការ ។ លើសពីនេះនៅក្រោមច្បាប់ព្រហ្មទណ្ឌ ទោះបីជាគមានភស្តុតាងថាចម្លើយសារភាពនោះមិនមែនបានមកដោយការបង្ខំក្តី គេមិនអាចប្រើវាដើម្បីផ្តន្ទាទោសជនជាប់ចោទបានឡើយ ប្រសិនបើវាមិនស៊ីសង្វាក់ជាមួយភស្តុតាង ផ្សេងទៀត ។

## មូលហេតុបន្ទាប់បន្សំនៃការធ្វើទារុណកម្ម

ក្នុងចំណោមហេតុផលជាច្រើនដែលប៉ូលីសអនុវត្តនូវការធ្វើទារុណកម្ម ខាងក្រោមនេះគឺជាករណី ធ្ងន់ធ្ងរបំផុត ហើយចាំបាច់ត្រូវមានការយកចិត្តទុកដាក់ជាបន្ទាន់។ ករណីនេះបានពង្រឹង និងគាំទ្របន្ថែម នូវមូលហេតុនៃការធ្វើទារុណកម្មដែលបានលើកឡើងខាងលើ។

## កង្វះខាតនៃបច្ចេកទេសក្នុងការអនុវត្តច្បាប់

ការធ្វើទារុណកម្ម គឺជាឥទ្ធិពលនៃបញ្ហាវ៉ាំរ៉ៃមួយនៅក្នុងប្រព័ន្ធនៃការអនុវត្តច្បាប់របស់ប្រទេស កម្ពុជា ដែលបង្ហាញឡើងដោយការការចាប់ខ្លួន និងការស៊ើបអង្កេតមិនសមស្រប។ វាហាក់ដូចជាមាន ការយល់ច្រឡំជាទូទៅក្នុងចំណោមប៉ូលីស អំពីថាតើពេលណាទើបការស៊ើបអង្កេតគួរតែកើតឡើងនោះ។ ជំនួសឱ្យការស៊ើបអង្កេតលើបទល្មើសមួយ ការប្រមូលភស្តុតាង និងបន្ទាប់មកការចាប់ជនខ្លួនជនសង្ស័យ ប៉ូលីស ជាញឹកញាប់អនុវត្តតាមរបៀបបញ្ច្រាសមកវិញ គឺចាប់ជនសង្ស័យមុននឹងធ្វើស៊ើបអង្កេត ។ ជាធម្មតាជនជាប់សង្ស័យត្រូវគេចាប់ខ្លួនផ្អែកលើពាក្យចចាមអារាម ឬការសង្ស័យជាជាងភស្តុតាង ហើយ បន្ទាប់មកប៉ូលីសបានរៀបចំរកភស្តុតាងបញ្ជាក់សំណុំរឿងនេះ ជាញឹកញាប់ដោយការបង្ខំយកចម្លើយ សារភាពពីអ្នកដែលត្រូវបានចាប់ខ្លួន។ មេធាវីមកពីអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជាម្នាក់បានពន្យល់ថា បញ្ហានេះគឺជាកិរិយាបទដែលកើតមានរាប់ទសវត្សមកហើយ នៅក្រោមរបបមុនៗដែលមានទស្សនៈថា "សូវចាប់ច្រឡំជាជាងលែងច្រឡំ"។ ការដែលប៉ូលីសពឹងផ្អែកលើចម្លើយសារភាពជាភស្តុតាងនោះ វាបញ្ជាក់ ពីកង្វះខាតនូវសមត្ថភាព ឬធនធានក្នុងការប្រើប្រាស់បច្ចេកទេសដទៃទៀត។

មនុស្សម្នាក់ដែលត្រូវបានចាប់ខ្លួនអាចត្រូវបានប៉ូលីសឃុំឃាំងរហូតដល់ ៤៨ ម៉ោង មុននឹងគេ នាំយកទៅតុលាការ ឬត្រូវដោះលែងមកវិញ។[១៣] ប៉ូលីសយល់ថា នេះមានន័យថាគេមានពេល ៤៨ ម៉ោង ដើម្បីប្រមូលភស្តុតាងដែលចាំបាច់ទាំងអស់ប្រឆាំងនឹងជនជាប់សង្ស័យ ហើយព្រោះហេតុដូច្នេះគេចាំបាច់ ត្រូវប្រើប្រាស់មធ្យោបាយទាំងអស់ដែលគេអាចប្រើបានដើម្បីប្រមូល "ភស្តុតាង" ឱ្យបានឆាប់រហ័ស។ បញ្ហានេះគេមិនបានគិតអំពីប្រការដែលថាប៉ូលីសគួរតែត្រូវមានភស្តុតាងខ្លះ *មុននឹង* គេចាប់ខ្លួនជនជាប់ សង្ស័យ ហើយនៅក្នុងករណីភាគច្រើន ប៉ូលីសត្រូវការដីកាចាប់ខ្លួនពីតុលាការដើម្បីអោយការចាប់ខ្លួន មានលក្ខណៈស្របច្បាប់ដែលទាមទារឱ្យមានការស៊ើបអង្កេតជាមុន។ ប្រសិនបើប៉ូលីសមានភស្តុតាងមុន ពេលចាប់ខ្លួន គេមិនជាចាំបាច់បង្ខំយកចម្លើយសារភាពដែលជួនកាលដោយប្រើអំពើហិង្សានោះឡើយ ។ ទោះបីជាយ៉ាងណាក្តី ជាញឹកញាប់ប៉ូលីស និងមន្ត្រីរដ្ឋាភិបាលបានរអ៊ូថា បញ្ញត្តិដែលអោយឃុំឃាំងរយៈ ពេល ៤៨ ម៉ោង ជាឧបសគ្គក្នុងការស៊ើបអង្កេតដែលបង្ខំឱ្យគេត្រូវស្វែងរកភស្តុតាងឱ្យបានឆាប់រហ័ស ។

[១៣] ច្បាប់ព្រហ្មទណ្ឌអន្តរកាលឆ្នាំ១៩៩២( មាត្រា ១៣) ច្បាប់ស្តីអំពីនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ១៩៩៣ ( មាត្រា ៤៧)

តរិយាបទនេះបាននាំទៅអោយមានការធ្វើវិសោធនកម្មច្បាប់មួយនៅឆ្នាំ ២០០១ ដើម្បីពន្យាពេលឃុំខ្លួន ២៤ ម៉ោងទៀតសម្រាប់បទល្មើសធ្ងន់ធ្ងរ។[១៤]

បទសម្ភាសន៍របស់លីកាដូជាមួយអ្នកទោសបានរកឃើញថា ជាញឹកញាប់ប៉ូលីសមិនបានអនុវត្តតាមនីតិវិធីនៃការចាប់ខ្លួន និងការស៊ើបអង្កេតឱ្យបានត្រឹមត្រូវឡើយ ដែលការនេះបានបង្កើននូវភាពប្រថុយប្រថានដែលថាជនជាប់សង្ស័យត្រូវគេធ្វើទារុណកម្ម ។ ក្នុងចំណោមអ្នកផ្តល់បទសម្ភាសន៍ចំនួន ២៨១ នាក់ដែលអះអាងអំពីការធ្វើទុក្ខបុកម្នេញដោយប៉ូលីស មានមនុស្ស ៣៨% ដែលត្រូវគេឃុំឃាំងអស់រយៈពេល៣ថ្ងៃ ឬ ច្រើនជាងនេះ ដោយរំលោភទៅលើច្បាប់ "សូមមើលតារាងទី៣" ។

**តារាងទី៣: រយៈពេលនៃការឃុំឃាំងដែលគេបានរាយការណ៍**




លើសពីនេះ មនុស្សមួយភាគធំត្រូវបានចាប់ខ្លួន ដោយគ្មានដីកាចាប់ខ្លួន។ ក្នុងចំណោមអ្នកជាប់ពន្ធនាគារចំនួន ២៨១ នាក់:

- ៣២,៧% ត្រូវគេចាប់ខ្លួនក្នុងអំឡុងពេលប៉ូលីសចូលឆែកឆេរ (គឺប៉ូលីសទៅឆែកឆេរទីកន្លែងជាក់លាក់មួយ ឬស្វែងរកចាប់ខ្លួនជនសង្ស័យដោយចេតនា) ៧៥% នៃក្រុមនេះបានអះអាងថា ប៉ូលីសមិនមានដីការចាប់ខ្លួនឡើយ។
- ២៤,២% ត្រូវគេចាប់ខ្លួននៅជិតកន្លែងកើតហេតុ មានន័យថាការចាប់ខ្លួនរបស់ពួកគេអាចត្រូវបានធ្វើឡើងដោយស្របច្បាប់ ដោយមិនបាច់មានដីការចាប់ខ្លួន។[១៥]

---

[១៤] វិសោធនកម្មខែ វិច្ឆិកា ឆ្នាំ២០០១ នៃមាត្រា ៣៨ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ(១៩៩៣)។ ការពន្យាពេល ២៤ ម៉ោងនៃការឃុំឃាំងសម្រាប់ប្រើប្រាស់តែនៅក្នុងកាលៈទេសៈមួយចំនួនប៉ុណ្ណោះ ក្នុងនោះរួមមាន ÷ បទឧក្រិដ្ឋធ្ងន់ធ្ងរ ភស្តុតាងច្បាស់លាស់ដែលទម្លាក់ ការចោទប្រកាន់ទៅលើជនសង្ស័យ ហើយនិងការឯកភាពជាលាយល័ក្ខអក្សរពីព្រះរាជអាជ្ញា។

[១៥] ប៉ូលីសត្រូវបានអនុញ្ញាតឱ្យធ្វើការចាប់ខ្លួន ដោយគ្មានដីកាចាប់ខ្លួននូវអ្នកដែលត្រូវគេចាប់បានក្នុងពេលប្រព្រឹត្តបទឧក្រិដ្ឋ (មាត្រា ៣៥ នៃច្បាប់ស្តីអំពីនីតិវិធីព្រហ្មទណ្ឌ និងមាត្រា ១៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល)។ គួរយកមកពិចារណាផងដែរ នូវប្រការដែលថា អ្នកជាប់ឃុំឃាំងខ្លះនៅក្នុងចំណាត់ប្រភេទនេះ អាចមានវត្តមាននៅកន្លែងដែលឧក្រិដ្ឋកម្មមួយកើតឡើង ប៉ុន្តែត្រូវគេយល់ច្រឡំថាជាជនល្មើស។

- ២១,៧% ត្រូវបាន"អញ្ជើញ"មកកាន់កន្លែងឃុំឃាំង ហើយត្រូវគេចាប់ខ្លួនតែម្តង។ ៨០%នៃមនុស្សក្រុមនេះបានអះអាងថាខ្លួនត្រូវគេឃុំឃាំងដោយគ្មានដីការចាប់ខ្លួន។
- ១៦,៧% ត្រូវបានឃុំឃាំងតាមរបៀបផ្សេងៗ ដែលក្នុងនោះរួមមានការនាំមកកន្លែងឃុំឃាំងរបស់ប៉ូលីសដោយមហាជន។

## កង្វះខាតសិទ្ធិចេញ-ចូលក្នុងកន្លែងឃុំឃាំងរបស់ប៉ូលីស

ជាញឹកញាប់ ប៉ូលីសឃុំឃាំងជនសង្ស័យឱ្យស្ថិតនៅឯកោ ដោយមិនអាចទាក់ទងទៅសមាជិកគ្រួសារ តំណាងផ្លូវច្បាប់ ឬអ្នកសង្កេតការណ៍សិទ្ធិមនុស្សឡើយ។ ទីកន្លែងឃុំឃាំងមនុស្សដែលត្រូវគេចាប់ខ្លួន ជាញឹកញាប់មិនត្រូវបានគេប្រាប់ឱ្យមនុស្សដទៃដឹងឡើយ ឬក៏ប្រសិនបើគេដឹង ក៏ប៉ូលីសបដិសេធ ឬក៏តាមដានយ៉ាងតឹងរ៉ឹង ចំពោះភ្ញៀវណាម្នាក់ដែលទៅសួរសុខទុក្ខពួកគេ។ នេះគឺជារឿងដែលគួរឱ្យព្រួយបារម្ភជាទីបំផុត អាស្រ័យដោយការធ្វើទុក្ខបុកម្នេញរបស់ប៉ូលីស ជាទូទៅ កើតឡើងនៅក្នុងដំណាក់កាលដំបូងៗនៃការឃុំឃាំង ជាពិសេស ក្នុងអំឡុងពេលនៃការសួរចម្លើយ។ ករណីនៃការធ្វើទារុណកម្មប្រមាណជា ៥៧% ដែលបានលើកឡើងនៅក្នុងឯកសារនេះ បានកើតឡើងក្នុងរយៈពេល ៤៨ ម៉ោងដំបូងនៃការឃុំឃាំង។ នៅពេលនេះ មនុស្សដែលត្រូវគេចាប់ខ្លួនគឺស្ថិតលើការមេត្តារបស់ប៉ូលីសដែលគ្រប់គ្រងពួកគេយ៉ាងពេញទំហឹង និងដោយផ្ទាល់មុខ ។ ប្រការនេះបង្កលក្ខណៈឱ្យការរំលោភបំពាន ដូចជាការធ្វើទារុណកម្មកាន់តែងាយស្រួលថែមទៀត។

ច្បាប់ និងគោលនយោបាយរបស់កម្ពុជា មិនបានចែងឱ្យច្បាស់លាស់ និងជាក់លាក់ឡើយ ថាតើនរណា ប្រសិនបើមាននោះ មានសិទ្ធិចូលសាកសួរអ្នកដែលស្ថិតនៅក្រោមការឃុំឃាំងរបស់ប៉ូលីស ។ ទោះបីជាទ្រឹស្តីនីតិវិធីរបស់ប៉ូលីសបានផ្តល់សិទ្ធិចេញ-ចូលដល់សមាជិកគ្រួសារ និងមេធាវីក្តី ជាញឹកញាប់ការអនុវត្តជាក់ស្តែងគឺជារឿងផ្សេងទៅវិញ ។ នីតិវិធីរបស់ប៉ូលីសក៏ផ្ទុយអំពីគោលនយោបាយជាក់ស្តែងរបស់រដ្ឋាភិបាល ដែលចែងថាគ្មាននរណាម្នាក់ក្រៅអំពី "ភ្នាក់ងារមានសមត្ថកិច្ចត្រូវបានអនុញ្ញាតឱ្យទាក់ទងជាមួយអ្នកជាប់ឃុំឃាំងក្នុងរយៈពេល ៤៨ ម៉ោងនៃការឃុំឃាំង ដែលជារយៈពេលដែលប៉ូលីសកំពុង"ប៉ុនប៉ងធ្វើការសួរចម្លើយ។"[១៦]

***សិទ្ធិចេញ-ចូលរបស់គ្រួសារ:*** ជួនកាលសមាជិកគ្រួសារត្រូវបានអនុញ្ញាតឱ្យចូលសាកសួរអ្នកជាប់ឃុំឃាំង ប៉ុន្តែជាញឹកញាប់គ្រាន់តែដើម្បីយកម្ហូបអាហារទៅឱ្យប៉ុណ្ណោះ អាស្រ័យដោយប៉ូលីសជាទូទៅមិនបាន

---

[១៦] របាយការរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ស្តីអំពីអនុសញ្ញាអន្តរជាតិប្រឆាំងការធ្វើទារុណកម្ម និការផ្តន្ទាទោស ឬការប្រព្រឹត្តទាំងឡាយណាដែលឃោរឃៅ អមនុស្សធម៌ ឬដែលនាំឱ្យបាត់បង់តម្លៃជាមនុស្ស ឆ្នាំ២០០៣ ទំព័រ១២៤

ផ្តល់ម្ហូបអាហារដល់មនុស្សដែលស្ថិតនៅក្នុងការឃុំឃាំងរបស់គេឡើយ ។ ញាតិសន្តានអាចត្រូវគេអនុញ្ញាតឱ្យចូលសួរសុខទុក្ខអ្នកជាប់ឃុំឃាំងក្នុងរយៈពេលយ៉ាងខ្លីបំផុត ហើយត្រូវគេណែនាំមិនឱ្យនិយាយជាមួយអ្នកជាប់ឃុំឡើយ ។ នីតិវិធីរបស់ប៉ូលីសចែងថាជនជាប់សង្ស័យមានសិទ្ធិប្រាស្រ័យទាក់ទងជាមួយញាតិសន្តាន និងមិត្តភក្តិ ដើម្បីផ្តល់ដំណឹងដល់ពួកគេអំពីការឃុំឃាំងរបស់ខ្លួន និងដើម្បីទទួលការមកសួរសុខទុក្ខរបស់ពួកគេ។[១៧] ក្នុងការអនុវត្តជាក់ស្តែង សិទ្ធិចេញ-ចូលបែបនេះកើតឡើងដោយកម្រ និងមិនទៀងទាត់ អាស្រ័យទៅលើទឹកចិត្តរបស់ប៉ូលីសម្នាក់ៗដែលប្រចាំការនៅពេលនោះ ។ ញាតិសន្តានអាចត្រូវគេសុំឱ្យសូកប៉ាន់ដើម្បីចូលជួបអ្នកជាប់ឃុំឃាំង ។ ប៉ូលីសទំនងជាមិនអនុញ្ញាតឱ្យសមាជិកគ្រួសារចូលជួបជនជាប់សង្ស័យដែលកំពុង ឬក៏ត្រូវបានធ្វើទារុណកម្មឡើយ ។

***សិទ្ធិចេញ-ចូលតាមផ្លូវច្បាប់:*** ច្បាប់របស់កម្ពុជាចែងថា"សិទ្ធិក្នុងការរកជំនួយពីមេធាវី ឬទីប្រឹក្សាច្បាប់ត្រូវបានធានាសម្រាប់ជនណាម្នាក់ ដែលត្រូវបានចោទប្រកាន់ពីបទមជ្ឈឹម ឬបទឧក្រិដ្ឋ" ហើយគ្មាននរណាម្នាក់ត្រូវគេឃុំឃាំងលើសពី៤៨ម៉ោង ដោយមិនមានសិទ្ធិជួបសមាជិកគ្រួសារ មេធាវី ឬតំណាងណាម្នាក់ឡើយ។[១៨] នៅពេលដែលត្រូវគេបញ្ជូនពីស្ថានីយ៍ប៉ូលីសទៅតុលាការ ជនជាប់សង្ស័យមានសិទ្ធិសុំឱ្យមានវត្តមានមេធាវី នៅក្នុងអំឡុងពេលនៃការសួរចម្លើយ ដោយចៅក្រមស៊ើបអង្កេត។[១៩] ប៉ុន្តែច្បាប់មិនបានបញ្ជាក់ថាជនជាប់សង្ស័យមានសិទ្ធិរកជំនួយផ្នែកច្បាប់ក្នុងខណៈដែលខ្លួនត្រូវគេឃុំឃាំងនៅស្ថានីយ៍ប៉ូលីស និងជាពិសេសក្នុងអំឡុងពេលនៃការសួរចម្លើយមុនពេលនាំខ្លួនទៅតុលាការ។ ទោះបីជាយ៉ាងណា នីតិវិធីប៉ូលីសចែងថា ជនជាប់សង្ស័យមានសិទ្ធិ "ប្រាស្រ័យទាក់ទងជាមួយអ្នកតំណាងផ្លូវច្បាប់ ហើយសុំឱ្យមានវត្តមាននៃបុគ្គលនោះក្នុងអំឡុងពេលនៃការសួរចម្លើយ។"[២០]

តាមពិត ជាទូទៅជនជាប់សង្ស័យពីបទល្មើសមិនអាចរកអ្នកតំណាងផ្នែកច្បាប់ ក្នុងខណៈពេលដែលខ្លួនត្រូវឃុំឃាំងដោយប៉ូលីសនោះឡើយ ។ ភ្នាក់ងារប៉ូលីសដែលប៉ុនប៉ងបង្ខំឱ្យជនជាប់សង្ស័យផ្តល់ចម្លើយសារភាពនោះទំនងជាមិនបានពន្យល់ពួកគេអំពីសិទ្ធិស្របច្បាប់របស់ពួកគេ ឬក៏ឆ្លើយតបចំពោះសំណើសុំឱ្យមានវត្តមានមេធាវីនោះឡើយ ។ ជាទូទៅមេធាវីខ្លួនឯងផ្ទាល់មិនមានបំណងចូលសួរសុខទុក្ខជនជាប់សង្ស័យនៅឯស្ថានីយ៍ប៉ូលីសទេ ។ មេធាវីនានានៅអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា (LAC) បាន

---

[១៧] នគរបាលជាតិនៃកម្ពុជា សៀវភៅនីតិវិធីសំរាប់នគរបាលយុត្តិធម៌ ទំព័រ ៣-១៧ និង ទំព័រ ៣-៥០

[១៨] ច្បាប់ព្រហ្មទណ្ឌអន្តរកាល ( មាត្រា១០)

[១៩] ច្បាប់ស្តីអំពីនីតិវិធីព្រហ្មទណ្ឌ ( មាត្រា៧៥)

[២០] នគរបាលជាតិនៃកម្ពុជា សៀវភៅនីតិវិធីសំរាប់នគរបាលយុត្តិធម៌ ទំព័រ ៣-១៧

ពន្យល់ថា ពួកគេជាទូទៅមិនបានដឹងដំណឹងអ្វីឡើយ នៅពេលដែលមនុស្សម្នាក់ត្រូវគេចាប់ខ្លួន និងឃុំឃាំង ហើយថាប្រសិនបើពតិមាននេះត្រូវបានរាយការណ៍ទៅឱ្យពួកគេ ជាធម្មតាពួកគេត្រូវបានបដិសេធមិនឱ្យជួបជនសង្ស័យឡើយ ។ តំណាងម្នាក់មកអំពីអង្គការជំនួយការផ្នែកច្បាប់មួយ គឺគំរោងអ្នកការពារក្តីកម្ពុជា (CDP) បានយល់ស្របចំពោះបញ្ហានេះដោយនិយាយថាៈ "ពួកគេ(ប៉ូលីស) មានការភ័យខ្លាចនៅពេលដែលមេធាវីចង់ចូលជួបកូនក្តីដែលស្ថិតក្នុងការឃុំឃាំងរបស់ប៉ូលីស។ ពួកគេនឹងពន្យារពេលការចូលជួប ហើយទៅសុំការឯកភាពពីចៅហ្វាយរបស់គេ ឬអាជ្ញាធរថ្នាក់លើសិន។"

បទសម្ភាសន៍ជាមួយប៉ូលីស និងបុគ្គលិកផ្នែកតុលាការបានបង្ហាញថា នីតិវិធីដែលមេធាវីត្រូវអនុវត្តដើម្បីសុំចូលជួបមនុស្សម្នាក់ ដែលស្ថិតនៅក្នុងការឃុំឃាំងរបស់ប៉ូលីសមិនមានភាពច្បាស់លាស់ឡើយ ។ ការអនុវត្តន៏នៅពេលបច្ចុប្បន្នសម្រាប់ជនសង្ស័យម្នាក់ក្នុងការស្វែងរកមេធាវី គឺជាការអនុវត្តដោយរអាក់រអួលដែលទាមទារនូវការដាក់ពាក្យសុំស្នើការឯកភាពពីតុលាការ ។ ប្រការនេះមិនមានកើតឡើងឡើយរហូតដល់ពេលដែលជនសង្ស័យត្រូវគេនាំយកទៅតុលាការ និងជាធម្មតាបន្ទាប់ពីត្រូវគេបញ្ជូនទៅពន្ធនាគារ ដើម្បីធ្វើការឃុំឃាំងជាបណ្តោះអាសន្ន ។ ភ្នាក់ងារប៉ូលីសហាក់ដូចជាមិនដឹងអំពីសិទ្ធិរបស់ជនសង្ស័យក្នុងការរកមេធាវីក្នុងអំឡុងពេលស្ថិតនៅក្នុងការឃុំឃាំងរបស់ប៉ូលីស ។ ប៉ូលីសម្នាក់ទៅជាស្រឡាំងកាំងនៅពេលដែលគាត់ត្រូវបានសួរថា តើគាត់នឹងធ្វើយ៉ាងដូចម្តេចប្រសិនបើមេធាវីសុំជួបជនជាប់សង្ស័យដែលជាប់នៅក្នុងការឃុំឃាំងនោះ ។ គាត់បានអះអាងថា ដំបូងគាត់ត្រូវសុំការអនុញ្ញាតពីព្រះរាជអាជ្ញាសិន ហើយបន្ទាប់មកគេនឹងរៀបចំការប្រជុំរួមមួយរវាងមេធាវី អធិការប៉ូលីស ព្រះរាជអាជ្ញា និងប៉ូលីសរូបនោះផ្ទាល់ ។ អ្វីដែលមិនត្រឹមត្រូវនោះ គឺប៉ូលីសនោះក៏បានសន្មត់ថា មេធាវីមិនគួរទៅជួបឬនិយាយជាមួយជនសង្ស័យតែម្នាក់ឯងឡើយ ។

តាមភាពជាក់ស្តែង ជាធម្មតាជនល្មើសមិនបានទទួលជំនួយផ្នែកច្បាប់ឡើយរហូតដល់ក្រោយពេលដែលគេត្រូវចាប់ខ្លួន និងឃុំឃាំងនៅដំណាក់កាលដំបូង ហើយអ្នកខ្លះត្រូវគេយកមកកាត់ក្តី ដោយគ្មានមេធាវីឡើយ។ អ្នកជាប់ឃុំឃាំងបណ្តោះអាសន្ន និងទណ្ឌិតជិត ៦០% ដែលត្រូវបានសម្ភាសន៏ដោយលីកាដូមិនមានតំណាងផ្លូវច្បាប់ក្នុងអំឡុងពេលនៃបទសម្ភាសន៏ ឬក៏ក្នុងអំឡុងពេលជុំនុំជំរះក្តីនោះឡើយ។[២១] យោងតាមមេធាវីរបស់ LAC បានឱ្យដឹងថា ជាញឹកញាប់ជនសង្ស័យត្រូវរង់ចាំមួយខែ ឬពីរខែបន្ទាប់ពីការចាប់ខ្លួន និងការឃុំឃាំងនៅដំណាក់កាលដំបូងមុននឹងខ្លួនបានជួបមេធាវីជាលើកទីមួយនោះ ។ ការពន្យារ

[២១] នៅក្នុងបទសម្ភាសន៏របស់លីកាដូ ទាំងអ្នកជាប់ឃុំឃាំងបណ្តោះអាសន្ន និងទណ្ឌិតត្រូវបានសាកសួរអំពីតំណាងផ្នែកច្បាប់របស់ពួកគេ : អ្នកជាប់ឃុំឃាំងបណ្តោះអាសន្នត្រូវបានសួរថា តើពួកគេមានមេធាវី ឬអត់ នៅពេលសម្ភាសន៏នោះ ហើយទណ្ឌិតត្រូវបានសួរថា តើគេមាន មេធាវី ឬអត់ នៅពេលសវនាការ។

ពេលក្នុងការស្វែងរកអ្នកតំណាងផ្នែកច្បាប់បែបនេះ គឺជាការរំលោភច្បាប់របស់កម្ពុជាដោយផ្ទាល់ ។[២២]

***សិទ្ធិរបស់បុគ្គលិកសិទ្ធិមនុស្សក្នុងការចូលជួបជនជាប់សង្ស័យ:*** បុគ្គលិកសិទ្ធិមនុស្សបានជួបប្រទះនូវការលំបាកប្រហាក់ប្រហែលគ្នាក្នុងការសុំចូលជួបជនសង្ស័យ ។ ពួកគេអាចទៅស្ថានីយ៍ប៉ូលីស ដើម្បីសាកសួរអំពីអ្នកជាប់ឃុំឃាំងជាក់លាក់ណាមួយ ប៉ុន្តែកម្រិតនៃពត៌មានដែលគេអាចទទួលបានមានការប្រែប្រួលយ៉ាងខ្លាំង ។ ពួកគេកម្រត្រូវបានគេអនុញ្ញាតឱ្យចូលជួប ឬសម្ភាសន៍ជនជាប់សង្ស័យនៅកន្លែងឃុំឃាំងណាស់ ។

**និទណ្ឌភាព: ការខកខានរបស់តុលាការក្នុងការប្រឈមមុខជាមួយនឹងការធ្វើទារុណកម្មរបស់ប៉ូលីស**

ប៉ូលីសអនុវត្តការធ្វើទារុណកម្ម ពីព្រោះពួកគេដឹងថាគេអាចរួចខ្លួន ។ វាគឺជារឿងកម្របំផុតដែលភ្នាក់ងារប៉ូលីសត្រូវបានគេយកមកផ្តន្ទាទោសចំពោះការធ្វើទារុណកម្មនោះ ។ ក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះមានករណីបែបនេះចំនួនបីដងតែប៉ុណ្ណោះ ។ នៅក្នុងករណីទី១តុលាការខេត្តស្វាយរៀង បានកាត់ទោសប៉ូលីសបីនាក់ឱ្យជាប់ពន្ធនាគារដោយព្យួរទោសកាលពីខែ មេសា ឆ្នាំ ២០០២ ពីបទធ្វើទារុណកម្មកុមារពីរនាក់ ។[២៣] ករណីពីរទៀត ដែលមួយពាក់ព័ន្ធនឹងការស្លាប់របស់ អៀត អឿន កាលពីឆ្នាំ ២០០១ នៅខេត្តព្រៃវែង (សូមមើលចំណុចនិយាយអំពី "ការស្លាប់នៅក្នុងកន្លែងឃុំឃាំងរបស់ប៉ូលីស" ខាងលើ) នៅមិនទាន់បានយកមកជំនុំជំរះក្តីនៅឡើយ ។

ក្នុងករណីដ៏កម្រដែលភ្នាក់ងារប៉ូលីសត្រូវគេដាក់ទោសនោះ ការកាត់ទោសដោយមានការអត់អោន ដូចជា ការព្យួរទោស ដែលមានន័យថាអ្នកប្រព្រឹត្តបទល្មើសមិនចាំបាច់ទៅនៅក្នុងពន្ធនាគារមួយថ្ងៃផងនោះគឺជារឿងធម្មតាទៅហើយ ។ ករណីចុងក្រោយដែលគេធ្លាប់ដឹងអំពីកងរាជអាវុធហត្ថម្នាក់ដែលបានជាប់នៅក្នុងពន្ធនាគារពិតប្រាកដ ដែលជាការដាក់ទណ្ឌកម្មចំពោះការប្រព្រឹត្តអំពើទារុណកម្មនោះគឺនៅឆ្នាំ ១៩៩៥ នៅពេលដែលកងរាជអាវុធហត្ថម្នាក់នៅខេត្តព្រៃវែង បានជាប់ក្នុងពន្ធនាគារ ចំនួនបួនខែពីបទវាយក្មេងអាយុ ១៣ ឆ្នាំម្នាក់ស្លាប់ក្នុងអំឡុងពេលសួរចម្លើយ ។[២៤]

---

[២២] កង្វះខាតមេធាវីនៅក្នុងប្រទេសកម្ពុជា បានធ្វើឱ្យបញ្ហានេះរិតតែធ្ងន់ធ្ងរទៅទៀត ។

[២៣] សំណុំរឿងនេះទាក់ទងនឹងសិស្សវិទ្យាល័យពីរនាក់ដែលត្រូវគេចាប់ខ្លួន និងវាយដួន១ដោយប៉ូលីសបីនាក់ ដែលស្រវឹងស្រា ដើម្បីបង្ខំឱ្យពួកគេសារភាពចំពោះការវាយប្រហារដែលមិនសមស្រប ។ ក្រោយមក សិស្សទាំងនោះត្រូវបានដោះលែងដោយគ្មានការចោទប្រកាន់អ្វីឡើយ ។ ប៉ូលីសត្រូវបានកាត់ទោសអំពីបទវាយដំលើរូបរាងរាងកាយ ដោយត្រូវជាប់ពន្ធនាគារព្យួរទោសចំនួនបីខែ និងត្រូវបានបញ្ជាឱ្យសងជម្ងឺចិត្តរួមគ្នាចំនួន ១៧៥ ដុល្លារ ទៅឱ្យគ្រួសារជនរងគ្រោះ ។ សូមអានព្រឹត្តិប័ត្រប្រចាំត្រីមាសរបស់ជំនួយការផ្នែកច្បាប់នៃកម្ពុជាលេខ៤ ខែកុម្ភៈឆ្នាំ២០០៣ ។

[២៤] កងរាជអាវុធហត្ថ ត្រូវបានចោទប្រកាន់ និងដាក់ទោសពីបទវាយដំលើរូបរាងកាយ ប៉ុន្តែមិនមែនពីបទមនុស្សឃាតឡើយ ។ គាត់បានទទួលទោសជាប់ពន្ធនាគាររយៈពេលពីរឆ្នាំ ប៉ុន្តែបានជាប់ឃុំពិតប្រាកដតែបួនខែប៉ុណ្ណោះ ហើយរយៈពេលក្រៅពីនោះត្រូវព្យួរទោស ។ សូមមើលរបាយការណ៍ "អន់ជាងមនុស្ស: ការធ្វើទារុណកម្មនៅក្នុងប្រទេសកម្ពុជា" របស់លីកាដូ ខែ មិថុនា ឆ្នាំ២០០០ ទំព័រ ១០៤ ។

មូលហេតុចំបងនៃនិទណ្ឌភាពដ៏ធ្ងររលុងរបស់អ្នកប្រព្រឹត្តអំពើទារុណកម្ម ដែលជាប៉ូលីសនោះរួមមាន÷

- ជនរងគ្រោះមានការភ័យខ្លាចមិនហ៊ាននិយាយអំពីការធ្វើទារុណកម្ម និងចម្លើយសារភាពដោយបង្ខំនៅចំពោះមុខព្រះរាជអាជ្ញា ឬចៅក្រម ឬដាក់ពាក្យបណ្តឹងប្រឆាំងនឹងអ្នកប្រព្រឹត្តបទល្មើសនោះឡើយ ។
- កង្វះខាតភស្តុតាងនៃការធ្វើទារុណកម្ម អាស្រ័យដោយការពន្យារពេលចំពោះមេធាវី បុគ្គលិកពេទ្យ ឬបុគ្គលិកសិទ្ធិមនុស្សនៅក្នុងការចូលជួបអ្នកជាប់ឃុំឃាំង ដែលក្រោយមកស្នាមជាំ និងសម្លាកផ្សេងៗជាធម្មតាវាជាសះស្បើយទៅហើយ ។
- ការរួមគំនិតរបស់តុលាការ÷ ការទទួលយកចម្លើយសារភាពដោយបង្ខំពីជនសង្ស័យសម្រាប់ធ្វើជាភស្តុតាងនៅក្នុងតុលាការ និងការខកខានមិនបានស៊ើបអង្កេតលើជនជាប់ចោទពីបទប្រព្រឹត្តអំពើទារុណកម្ម ។

មេធាវីម្នាក់មកពី CDP បានពន្យល់ថា វាមានការពិបាកក្នុងការលើកឡើងនូវបញ្ហានៃការធ្វើទារុណកម្ម និងចម្លើយសារភាពដោយបង្ខំនៅក្នុងអំឡុងពេលជំនុំជំរះក្តីលើជនសង្ស័យ ។ ជាធម្មតាតុលាការមិនព្រមទទួលយកអំណះអំណាងបែបនេះឡើយ ហើយទាមទារគេឱ្យដាក់សំណុំរឿងដោយឡែកមួយទៀត ដើម្បីប្តឹងប៉ូលីសដែលនឹងត្រូវធ្វើសវនាការនៅថ្ងៃក្រោយ (ដែលកម្រនឹងកើតមានណាស់)។ តាមពិតការលើកឡើងនូវប្រធានបទនៃការធ្វើទារុណកម្មបានបញ្ជាក់ថា វាគឺជាមធ្យោបាយដែលមិនមានប្រសិទ្ធិភាពសម្រាប់មេធាវី ។ តុលាការហាក់ដូចជាមិនចាប់អារម្មណ៏ចំពោះពាក្យចោទប្រកាន់អំពីចម្លើយសារភាពដោយបង្ខំឡើយ សូម្បីតែនៅក្នុងករណីខ្លះមានភស្តុតាងមើលឃើញជាក់ស្តែងថាការធ្វើទារុណកម្មបានកើតមានក៏ដោយ ។

ជនរងគ្រោះដែលហ៊ានត្អូញត្អែរអំពីការធ្វើទារុណកម្ម ត្រូវប្រឈមមុខនឹងភាពប្រថុយប្រថាននៃការសងសឹកពីអ្នកធ្វើទារុណកម្មមកលើពួកគេ ពីប៉ូលីសដែលជាសហការីរបស់គេ ឬក៏សូម្បីតែពីតុលាការផងដែរ ។ ករណីជាឧទាហរណ៏មួយ គឺការជំនុំជំរះក្តីមួយនៅខេត្តស្វាយរៀង កាលពីបីឆ្នាំមុនដែលក្នុងអំឡុងពេលនោះជនជាប់ចោទបានត្អូញត្អែរថា គាត់ត្រូវប៉ូលីសធ្វើទារុណកម្មដើម្បីបង្ខំឱ្យសារភាព ។ ចៅក្រមបានកោះហៅប៉ូលីសឡើងតុលាការ ហើយសុំឱ្យពួកគេធ្វើការពន្យល់ ។ ប៉ូលីសបានបដិសេធការចោទប្រកាន់នោះ ។ ចៅក្រមបានបន្ថែមបទចោទប្រកាន់មួយទៀតទៅលើជនជាប់ចោទតាមតែអំពើចិត្ត គឺបទ

បរិហារកេរ្តិ៍ ហើយក៏បានកាត់ក្តីឱ្យគាត់ជាប់ទោសដាក់ពន្ធនាគារចំនួនមួយខែបន្ថែមពីលើការកាត់ទោសដែលខ្លួនបានទទួលសម្រាប់បទចោទប្រកាន់ដើមដំបូងមកលើរូបគេ ។[២៥]

សារយ៉ាងច្បាស់លាស់ដែលតុលាការបញ្ជូនទៅឱ្យប៉ូលីសនោះ គឺថាការធ្វើទារុណកម្មដើម្បីបង្ខំយកចម្លើយសារភាពអាចទទួលយកបាន ហើយថាអ្នកប្រព្រឹត្តអំពើទារុណកម្ម នឹងមិនត្រូវបានគេឱ្យទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនឡើយ ។

**ឧទាហរណ៍នៃការរួមគំនិតរបស់តុលាការដោយការមិនអើពើចំពោះភស្តុតាង**

នៅក្រុងកំពង់សោម ប៉ូលីសបីនាក់បានចាប់ខ្លួនជនសង្ស័យម្នាក់ផ្អែកលើការរៀបរាប់ដែលផ្តល់ដោយជនរងគ្រោះអំពីអំពើប្លន់មួយ ។ ជនសង្ស័យត្រូវគេធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរនៅក្នុងការឃុំឃាំងរបស់ប៉ូលីស ហើយបានបង្ហាញនូវស្នាមរបួស ដែលមើលឃើញជាក់ស្តែងនៅពេលដែលគេបង្ហាញមុខនៅក្នុងតុលាការបីថ្ងៃក្រោយពីការចាប់ខ្លួនៈ ឧទាហរណ៍ ដូចជាមុខរបស់គាត់ដែលហើមជាំខ្មៅជាដើម ។ នៅពេលដែលតុលាការសួរអំពីស្ថានភាពរបស់គាត់ ជនជាប់ចោទបាននិយាយថាប៉ូលីសបានធ្វើទារុណកម្មគាត់ ។ ជាមួយគ្នានេះដែរ ជនរងគ្រោះដោយអំពើប្លន់បានប្រាប់ប៉ូលីស និងមន្ត្រីតុលាការថាពួកគេបានចាប់ខ្លួន និងឃុំឃាំងមនុស្សច្រលំ ។ ទោះបីជាយ៉ាងណាក្តី ជនជាប់ចោទត្រូវគេដាក់ពន្ធនាគារមុនពេលជំនុំជំរះក្តីអស់រយៈពេលបីខែកន្លះមុននឹងតុលាការដោះលែង ។ ជនរងគ្រោះមិនបានដាក់ពាក្យបណ្តឹងប្រឆាំងនឹងអ្នកធ្វើទារុណកម្មដែលជាប៉ូលីសនោះឡើយ ពីព្រោះគាត់និយាយថាគាត់គ្មានប្រាក់គ្រប់គ្រាន់ហើយនៅ "ឯកោ" ។ អ្នកធ្វើទារុណកម្មគាត់មិនដែលត្រូវបានយកមកកាត់ទោសឡើយ ។

## ឥរិយាបថសង្គម : បទល្មើស និងយុត្តិធម៌នៅក្នុងប្រទេសកម្ពុជា

ឥរិយាបថសង្គម អាចបញ្ជាក់បន្ថែមអំពីការអនុវត្តការធ្វើទារុណកម្ម នៅក្នុងការឃុំឃាំងរបស់ប៉ូលីស ។ ដោយពិនិត្យទៅលើប្រវត្តិសាស្ត្រថ្មីៗដែលគួរឱ្យរន្ធត់របស់ប្រទេសកម្ពុជា សង្គមចាត់ទុកយ៉ាងសាមញ្ញថាអំពើហិង្សាគឺជាលក្ខណៈធម្មតាមួយនៃជីវិត ។ បញ្ហានេះរួមជាមួយនឹងបញ្ហានៃឧក្រិដ្ឋកម្ម និងប្រព័ន្ធតុលាការពុករលួយ និងទន់ខ្សោយ ទីបំផុតធ្វើឱ្យការរំលោភបំពានរបស់ជនសង្ស័យពីបទឧក្រិដ្ឋចេះតែកើតមានជាបន្តទៀត ។ លើសពីនេះ គេអាចវែកញែកហេតុផលថា វាមានឥទ្ធិពលផ្នែកវប្បធម៌ដ៏ទូលំទូលាយមួយដែលក្នុងកម្រិតមួយនោះ ការរំលោភបំពានលើអ្នកគ្មានអំណាចដោយអ្នកមានអំណាចត្រូវបានទទួលយកនៅក្នុងសង្គមកម្ពុជា ។

វាមិនមានការពន្យល់អំពីលទ្ធផលនៃឥរិយាបថបែបនេះឱ្យបានប្រសើរជាងនៅពេលដែលសាធារណៈជនស្វែងរកយុត្តិធម៌ដោយខ្លួនឯងឡើយ ។ ការវាយប្រហារ និងការសម្លាប់ជនសង្ស័យពីបទល្មើសដោយហ្វូងមនុស្សបានបង្ហាញនូវការរំពឹងទុករបស់សង្គមអំពីរបៀបផ្តន្ទាទោស និងវិធីដើម្បីបញ្ឈប់អំពើ

---

[២៥] បទសម្ភាសន៍ជាមួយ មេធាវីជំនួយផ្នែកច្បាប់នៃកម្ពុជា ។

ល្មើសមួយ ។ អង្គការសហប្រជាជាតិបានកត់ត្រាជាឯកសារនូវឧប្បត្តិហេតុ ចំនួន ៦៥ ករណីនៃអំពើហិង្សាដែលប្រព្រឹត្តដោយហ្វូងមនុស្សនៅក្នុងប្រទេសកម្ពុជា ចាប់ពីខែ ឧសភា ឆ្នាំ១៩៩៩ ដល់ខែ ឧសភា ឆ្នាំ២០០២ ដែលក្នុងនោះរួមមានការវាយប្រហារដែលបានកើតឡើងចំនួនបីដងក្នុងចន្លោះ ខែ ធ្នូ ឆ្នាំ២០០១ និងខែ ឧសភា ឆ្នាំ២០០២ ។[២៦]

ប៉ូលីសគឺជាផ្នែកមួយនៃសង្គម និងជារូបភាពឆ្លុះបញ្ចាំងនូវទស្សនៈវិស័យនេះ។ ជួនកាលប៉ូលីសជួយ ឬឈរមើលការវាយប្រហាររបស់ហ្វូងមនុស្សដោយឥតមានអើពើអ្វីឡើយ ។ ក្នុងរយៈពេលម្តងម្កាល ពួកគេប្រើប្រាស់ "ហ្វូងមនុស្ស" ជារូបភាពមួយនៃការធ្វើទារុណកម្ម ។

**ឧទាហរណ៍ ការវាយប្រហារដោយហ្វូងមនុស្សជារូបភាពមួយនៃការធ្វើទារុណកម្ម**

បុរសម្នាក់ដែលត្រូវគេចាប់ខ្លួននៅខេត្តកំពង់ចាម កាលពីឆ្នាំ២០០១ បានបញ្ជាក់ថាៈ "នៅពេលខ្ញុំកំពុងហូបបាយល្ងាច មានមនុស្សបួន-ប្រាំនាក់មកចាប់ខ្លួនខ្ញុំ។ ពួកគេបានយកខ្សែចងដៃខ្ញុំទៅក្រោយ ហើយយកខ្ញុំទៅប៉ុស្តិ៍ប៉ូលីស។ នៅតាមផ្លូវពួកគេវ៉ៃខ្ញុំយ៉ាងធ្ងន់ធ្ងរ។ រំពេចនោះប៉ូលីសបានមកដល់ ប៉ុន្តែប៉ូលីសមិនបានជួយខ្ញុំទេ។ ផ្ទុយទៅវិញ ប៉ូលីសបានវាយខ្លួនខ្ញុំប្រាំ-ប្រាំមួយព្រនង់ ហើយទាត់ខ្ញុំចំដើមទ្រូង។ ពួកគេព្យាយាមឱ្យខ្ញុំសារភាព ហើយសួរថាៈ" ហ្គេងប្លន់នៅកន្លែងណា?" នៅពេលពួកគេឃើញប៉ូលីសធ្វើទារុណកម្មខ្ញុំ ពួកគេបន្តធ្វើទារុណកម្មខ្ញុំ ហើយជួយប៉ូលីសទៀត។ ពួកគេទាត់ និងវ៉ៃខ្ញុំយ៉ាងខ្លាំង ហើយមានម្នាក់ទៀតយកកាំបិតអារដៃខ្ញុំ។ ក្រោយមកគេបញ្ជូនខ្ញុំទៅអធិការដ្ឋាននគរបាលដើម្បីសួរចម្លើយ ។ នៅពេលខ្ញុំទៅដល់ទីនោះ ខ្ញុំអត់មានសារភាពអ្វីទាំងអស់ ដូច្នេះប៉ូលីសបណ្តោយឱ្យគេវ៉ៃខ្ញុំទៀត ។ ម្តងនេះគេបានវ៉ៃខ្ញុំយ៉ាងខ្លាំងរហូតដល់ខ្ញុំព្រមនិយាយអ្វីដែលគេចង់បាន ។ ខ្ញុំត្រូវរបួសយ៉ាងធ្ងន់ ហើយប៉ូលីសត្រូវបញ្ជូនខ្ញុំទៅមន្ទីរពេទ្យស្រុកដើម្បីព្យាបាល ។ ខ្ញុំសម្រាកនៅក្នុងមន្ទីរពេទ្យចំនួនបីយប់ ហើយនៅពេលដែលខ្ញុំនៅទីនោះគេបានដាក់ខ្នោះដៃខ្ញុំ។ បន្ទាប់មកប៉ូលីសបានឱ្យខ្ញុំសារភាព ហើយបង្ខំឱ្យខ្ញុំផ្តិតមេដៃ។

អ្នកទោសជាច្រើននាក់ដែលត្រូវបានសម្ភាសន៍ដោយលីកាដូ បានពន្យល់ថា មូលហេតុមួយដែលខ្លួនត្រូវរកធ្វើទុក្ខបុកម្នេញក្នុងពេលឃុំឃាំងនោះ គឺថាប៉ូលីសស្អប់ខ្ពើមពួកគេ ហើយចង់ដាក់ទណ្ឌកម្មពួកគេ ។ ឧទាហរណ៍ អ្នកទោសម្នាក់នៅខេត្តកំពង់ឆ្នាំង បាននិយាយថា ប៉ូលីសម្នាក់បានវាយគាត់ដោយសារគាត់ជាអតីតអ្នកទោស ។ គេនិយាយថាៈ "ប៉ូលីសបានចូលក្នុងបន្ទប់ឃុំឃាំង ហើយសួរថា "តើគេដោះលែងហ្អែងពីគុកមែនទេ?" ខ្ញុំឆ្លើយថា "បាទ" ហើយប៉ូលីសនោះក៏ដាល់ខ្ញុំចំមុខ និងសៀតគង្កាធ្វើឱ្យខ្ញុំដួលទៅលើដី។"

---

[២៦] តំណាងពិសេស របស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា "ការចងព្យួរតាមដងផ្លូវនៅក្នុងប្រទេសកម្ពុជា" ថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ២០០២ និង"ស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា" ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ២០០២ (កថាខ័ណ្ឌ១៦)

### ផលវិបាកនៃការធ្វើទារុណកម្ម

ការធ្វើទារុណកម្មបណ្តាលឱ្យមានផលវិបាកយ៉ាងធ្ងន់ធ្ងរសម្រាប់ជនរងគ្រោះទាំងផ្លូវកាយ និង ផ្លូវចិត្ត ព្រមទាំងផលវិបាកដ៏ធ្ងន់ធ្ងរសម្រាប់គ្រួសារជនរងគ្រោះ និងសង្គម ។

### ផលវិបាកផ្លូវកាយ

ឥទ្ធិពលនៃការវាយទាត់ធាក់ ឬរូបភាពផ្សេងទៀតនៃការធ្វើទារុណកម្មអាចរួមមាន របួសក្បាល ខូចសរីរាង្គខាងក្នុង បាក់ឆ្អឹង ស្នាមជាំ ស្នាមមុត និងដំបៅ ហើយប្រសិនបើការរំលោភនោះវាធ្ងន់ធ្ងរ វាបណ្តាលអោយពិការភាពមួយជីវិត (ដូចជាខ្វាក់ភ្នែក ឬក៏ថ្លង់) ឬរហូតដល់ស្លាប់ ។

### ផលវិបាកផ្លូវចិត្ត

ក្រៅអំពីរបួសស្នាមលើរាងកាយ ការធ្វើទារុណកម្មបណ្តាលឱ្យមានអាការៈរោគផ្លូវចិត្តយ៉ាង ធ្ងន់ធ្ងរសម្រាប់ជនរងគ្រោះភាគច្រើន ។ អាការៈរោគទាំងនេះ រួមមាន ការភ័យខ្លាច ការធុញថប់ ក្នុងអារម្មណ៍ និងការព្រួយបារម្ភ ការធ្លាក់ទឹកចិត្ត បញ្ហាដំណេក ដូចជាយល់សប្តិអាក្រក់ ឬដេកមិនលក់។ ផលវិបាកផ្លូវចិត្តនេះអាចអូសបន្លាយជាច្រើនឆ្នាំ ហើយវាប៉ះពាល់ចំពោះសុខភាព និងជីវិតរបស់ជនរងគ្រោះ និងគ្រួសាររបស់គេយ៉ាងធ្ងន់ធ្ងរ ។

### ផលវិបាកផ្នែកសង្គម

ការធ្វើទារុណកម្ម និងអំពើហិង្សាតាមរូបភាពដទៃទៀតបានធ្វើអោយសីលធម៌ និងការគោរព ចំពោះជីវិតរបស់មនុស្សថយចុះ ហើយលើកទឹកចិត្តដល់ឥរិយាបថទូទៅមួយនៅក្នុងសង្គម ថាអំពើហិង្សា អាចទទួលយកបាន ។ ការធ្វើទារុណកម្មបានធ្វើឱ្យខូចនូវតម្លៃប្រពៃណី និងសាសនារបស់កម្ពុជា ហើយ វារារាំងចំពោះការរីកលូតលាស់របស់សង្គមផ្អែកវិធាននៃច្បាប់ ហើយនិងជំនឿទុកចិត្ត និងការគោរពគ្នា ទៅវិញទៅមករវាងសមាជិកទាំងអស់នៅក្នុងសង្គម ។ ការយល់ឃើញថាអាជ្ញាធរអាចធ្វើអ្វីៗទាំងអស់ ដែលគេចង់ធ្វើដោយគ្មានក្តីមេត្តា នោះវានឹងបង្កើតឡើងនូវអសន្តិសុខ និងការភ័យខ្លាចនៅក្នុងសង្គម ។

## ច្បាប់កម្ពុជា និងច្បាប់អន្តរជាតិប្រឆាំងនឹងការធ្វើទារុណកម្ម

រដ្ឋាភិបាលកម្ពុជា នៅជាប់កាតព្វកិច្ចដោយការសន្យាទាំងនៅក្នុងស្រុក និងអន្តរជាតិ ដើម្បីការពារ ជនជាប់សង្ស័យកុំឱ្យគេធ្វើទារុណកម្មទាំងក្នុងអំឡុងពេលនៃការចាប់ខ្លួន និងការឃុំឃាំង ។

## ច្បាប់កម្ពុជា

រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ របស់កម្ពុជាចែងថា ÷ "ច្បាប់ការពារមិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ" ហើយបានហាមឃាត់យ៉ាងដាច់ខាតនូវការប្រព្រឹត្តមិនគប្បីចំពោះជនជាប់ឃុំឃាំង និងជនជាប់ពន្ធនាគារ ។[២៧] ដូចជានៅក្នុងប្រទេសជាច្រើនដែរ ប្រទេសកម្ពុជាមិនមានច្បាប់ណាមួយដែលបានចែងពីបទល្មើសនៃ "ការធ្វើទារុណកម្ម" ឡើយ ។ ទោះបីជាយ៉ាងណាក្តីនៅក្រោមច្បាប់ព្រហ្មទណ្ឌកម្ពុជា អ្នកប្រព្រឹត្តបទល្មើសអាចមានទោសចំពោះបទល្មើសជាក់លាក់ណាមួយនៃការធ្វើទារុណកម្មមានជាអាទិ៍ ការឃុំឃាំងមនុស្សខុសច្បាប់ ការរំលោភលើរាងកាយ ការរំលោភសេពសន្ថវៈ និង មនុស្សឃាត ។ល។

ច្បាប់ព្រហ្មទណ្ឌអន្តរកាលនៅឆ្នាំ ១៩៩២ ចែងថា "គ្មានជនជាប់ឃុំណាម្នាក់ត្រូវទទួលទណ្ឌកម្ម ឬការប្រព្រឹត្តទាំងឡាយណាដែលឃោរឃៅ អមនុស្សធម៌ ឬនាំអោយបាត់បង់តម្លៃជាមនុស្ស ឬក៏ត្រូវគេវាយដំនិងធ្វើទារុណកម្មឡើយ ។ "(មាត្រា១២.១) ។ តាមផ្លូវច្បាប់ ភ្នាក់ងារសាធារណៈក្នុងនោះរួមមានប៉ូលីស និងយោធាដែលប្រព្រឹត្តអំពើទារុណកម្មនឹងត្រូវដាក់ទណ្ឌកម្មឱ្យជាប់ពន្ធនាគារពីមួយឆ្នាំទៅប្រាំឆ្នាំ ។[២៨] ទាំងរដ្ឋធម្មនុញ្ញ និងច្បាប់ព្រហ្មទណ្ឌហាមឃាត់នូវការប្រើប្រាស់ចម្លើយសារភាពដែលបានមកដោយការបង្ខិតបង្ខំតាមផ្លូវកាយ ឬផ្លូវចិត្ត ។[២៩]

សរុបមក ការការពារបុគ្គលនានាអំពីការធ្វើទារុណកម្មត្រូវបានចែងយ៉ាងជាក់លាក់នៅក្នុងច្បាប់របស់កម្ពុជា ។ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ក៏ដូចជាច្បាប់ស្តីអំពីនីតិវិធីព្រហ្មទណ្ឌក៏បានចែងនូវនីតិវិធីត្រឹមត្រូវសម្រាប់ការចាប់ខ្លួន និងការឃុំឃាំងជនជាប់សង្ស័យពីបទល្មើស ។

## ច្បាប់អន្តរជាតិ

ប្រទេសកម្ពុជា បានចុះហត្ថលេខាលើអនុសញ្ញាអន្តរជាតិប្រឆាំងការធ្វើទារុណកម្ម និងការផ្តន្ទាទោស ឬការប្រព្រឹត្តទាំងឡាយណាដែលឃោរឃៅ អមនុស្សធម៌ ឬដែលនាំឱ្យបាត់បង់តម្លៃជាមនុស្សកាលពីឆ្នាំ១៩៩២ ។ នៅក្រោមអនុសញ្ញានេះប្រទេសកម្ពុជាចាំបាច់ត្រូវចាត់វិធានការប្រឆាំងនឹងការធ្វើទារុណកម្ម ហើយនិងអំពើ "ឃោរឃៅ អមនុស្សធម៌ ឬ ដែលនាំឱ្យបាត់បង់តម្លៃជាមនុស្ស" ដទៃទៀត ។ យោងតាមមាត្រា ២ នៃអនុសញ្ញានេះ ប្រទេសកម្ពុជាត្រូវ "ប្រកាន់យកនូវរាល់វិធានការស័ក្តិសិទ្ធិផ្នែកផ្លូវច្បាប់ ផ្នែករដ្ឋបាល ផ្នែកតុលាការ និងវិធានការផ្សេងទៀត ដើម្បីបង្ការអំពើទារុណកម្ម។" មាត្រានេះ

[២៧] រដ្ឋធម្មនុញ្ញ (មាត្រា៣៨)

[២៨] ច្បាប់ព្រហ្មទណ្ឌអន្តរកាល(មាត្រា២២. ២ និងមាត្រា៥៧)

[២៩] រដ្ឋធម្មនុញ្ញ (មាត្រា៣៨. ៥) និងច្បាប់ព្រហ្មទណ្ឌអន្តរកាល (មាត្រា២៤.៣)

ក៏បានចែងថា បទបញ្ជាពីមន្ត្រីថ្នាក់លើ ឬអាជ្ញាធរសាធារណៈ មិនមែនជាមូលហេតុថា ការធ្វើទារុណកម្មត្រឹមត្រូវតាមច្បាប់នោះឡើយ ។

ជាពិសេស មាត្រា ៤ និងមាត្រា ១២ នៃអនុសញ្ញានេះ ក៏តម្រូវឱ្យប្រទេសកម្ពុជាៈ

- ធានាថា រាល់អំពើនៃការធ្វើទារុណកម្មទាំងអស់ (ក្នុងនោះរួមមានការប៉ុនប៉ងប្រព្រឹត្តការធ្វើទារុណកម្ម ឬការរួមគំនិត ឬការចូលរួមនៅក្នុងការធ្វើទារុណកម្ម) គឺជាបទល្មើសនៅក្រោមច្បាប់ព្រហ្មទណ្ឌរបស់ខ្លួន ។ បទល្មើសទាំងនេះត្រូវតែអាចដាក់ទណ្ឌកម្មដែលសមស្របដោយពិនិត្យទៅលើចរិតធ្ងន់ធ្ងរនៃអំពើល្មើស ។
- ធានាថា អាជ្ញាធររបស់ខ្លួនធ្វើការស៊ើបអង្កេតជាបន្ទាន់ និងដោយយុត្តិធម៌នៅពេលណាក៏ដោយដែលមានមូលដ្ឋានសមរម្យល្មមនឹងអោយជឿបានថា មានអំពីទារុណកម្មប្រព្រឹត្តឡើងមែន ។

កតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងនយោបាយន ដែលផ្តល់សច្ចាប័នដោយប្រទេសកម្ពុជានៅឆ្នាំ១៩៩២ ក៏តម្រូវឱ្យមានវិធានការដើម្បីការពារមនុស្សអំពីការរធ្វើទារុណកម្ម និងការចាប់ខ្លួន ឬការឃុំឃាំងតាមទំនើងចិត្ត ។[៣០]

ប៉ូលីសមានភារកិច្ចតាមផ្លូវច្បាប់របស់ប្រទេសកម្ពុជា ក្នុងការគោរពតាមក្រមសីលធម៌អង្គការសហប្រជាតិសម្រាប់មន្ត្រីអនុវត្តច្បាប់ ។[៣១] មាត្រា ៥ ចែងថាៈ "គ្មានមន្ត្រីអនុវត្តច្បាប់ណាម្នាក់អាចប្រព្រឹត្តញុះញង់ ឬក៏អត់អោនចំពោះអំពើទារុណកម្ម និងការផ្តន្ទាទោស ឬការប្រព្រឹត្តទាំងឡាយណាដែលឃោរឃៅ អមនុស្សធម៌ ឬដែលនាំឱ្យបាត់បង់តម្លៃជាមនុស្ស" នោះឡើយ ។

## សិទ្ធិចេញ-ចូលកន្លែងឃុំឃាំងរបស់ប៉ូលីស និងការត្រួតពិនិត្យប្រកបដោយឯករាជ្យៈ យន្តការដើម្បីកាត់បន្ថយការធ្វើទារុណកម្មរបស់ប៉ូលីស

ការធ្វើទារុណកម្មត្រូវបានគេប្រព្រឹត្តយ៉ាងងាយស្រួលទៅលើជនជាប់ឃុំឃាំង ដែលស្ថិតនៅឯកោដោយមិនត្រូវគេអនុញ្ញាតឱ្យនិយាយជាមួយនរណាម្នាក់ ដូចជាគ្រួសាររបស់ខ្លួន មេធាវី ឬក៏បុគ្គលិកសិទ្ធិមនុស្ស ។ កង្វះខាតនូវសិទ្ធិចេញចូលក្នុងកន្លែងឃុំឃាំងរបស់ប៉ូលីស ហើយនិងការមិនទទួលខុសត្រូវ

[៣០] មាត្រា៧ និង៩

[៣១] សូមមើលច្បាប់ព្រហ្មទណ្ឌអន្តរកាល (មាត្រា៦.១)

របស់ភ្នាក់ងារប៉ូលីស គឺជាឧបសគ្គចំបងចំពោះការការពារជនជាប់ឃុំឃាំង ។

ដូចជាបាន លើកឡើងនៅក្នុងឯកសារនេះ នៅពេលបច្ចុប្បន្ន ប៉ូលីសដែលជាអ្នកឃុំឃាំងជនសង្ស័យនៅក្នុងកន្លែងឃុំឃាំងរបស់ប៉ូលីស ពួកគេមានរយៈពេល ៤៨ ម៉ោង ដើម្បីបង្ខំយកចម្លើយសារភាពដោយគ្មានការទទួលខុសត្រូវ ។ នៅក្នុងករណីភាគច្រើន គេមិនបានដឹងថាមនុស្សម្នាក់ត្រូវបានធ្វើទារុណកម្មដោយប៉ូលីសឡើយរហូតដល់ប្រហែលជាមួយខែ ក្រោយមកទើបគេដឹងនៅពេលដែលបុគ្គលិកសិទ្ធិមនុស្ស ឬមេធាវីសម្ភាសន៏ជនរងគ្រោះនៅក្នុងពន្ធនាគារ ។ លើសពីនេះអ្នកប្រព្រឹត្តិបទល្មើសកម្រត្រូវបានគេយកមកកាត់ទោសណាស់ អាស្រ័យដោយកង្វះខាតភស្តុតាងនៃការធ្វើទារុណកម្មនៅពេលនេះ ហើយនិងកង្វះខាតនូវឆន្ទៈរបស់តុលាការ និងនយោបាយ ។

ហេតុដូច្នេះហើយ វិធានការក្នុងការទប់ស្កាត់អំពើទារុណកម្មតម្រូវឱ្យមានជាបន្ទាន់។ ជាដំបូងសិទ្ធិរបស់ជនជាប់ឃុំឃាំងក្នុងការទទួលភ្ញៀវចូលសួរសុខទុក្ខនៅក្នុងការឃុំឃាំងរបស់ប៉ូលីស ដែលជាវិធីមួយដើម្បីរារាំង ឬកាត់បន្ថយការធ្វើទុក្ខបុកម្នេញរបស់ប៉ូលីសនោះគួរតែត្រូវបានធានាដោយច្បាប់ និងនីតិវិធីរបស់ប៉ូលីស។ សមាជិកគ្រួសារ និងមេធាវី គួរតែត្រូវបានអនុញ្ញាតឱ្យចូលជួប និងនិយាយជាមួយជនជាប់ឃុំឃាំង ។ អាស្រ័យដោយកង្វះខាតនូវមេធាវីនៅក្នុងប្រទេសកម្ពុជា អង្គការសិទ្ធិមនុស្សគួរតែត្រូវបានអនុញ្ញាតឱ្យជួបជនជាប់ឃុំឃាំង ។ គោលការណ៍ដែលគួរតែគោរពតាមនោះគឺថាជនសង្ស័យ ឬជនជាប់ចោទម្នាក់ៗមានសិទ្ធិជួបជាមួយសមាជិកគ្រួសារ មេធាវី និងតំណាងដទៃទៀតនៅគ្រប់ដំណាក់កាលនៃការស៊ើបអង្កេតបទឧក្រិដ្ឋ ។[៣២]

ទីពីរ មានតម្រូវការចំបាច់មួយក្នុងការចេញចូលស្ថានីយ៍ប៉ូលីសឱ្យបានទៀងទាត់ពេលវេលា ។ ការធ្វើនេះនឹងបញ្ជូននូវសារដ៏ច្បាស់លាស់មួយចំពោះប៉ូលីសថា សិទ្ធិចេញចូលគួរតែត្រូវបានអនុញ្ញាតនៅដំណាក់កាលឃុំឃាំង ហើយអ្វីដែលសំខាន់នោះគឺដើម្បីរារាំងនូវការធ្វើទារុណកម្មជនសង្ស័យ ។ វាក៏មានតម្រូវការជាបន្ទាន់ផងដែរ ឱ្យមានការត្រួតពិនត្យទៀងទាត់នូវស្ថានភាពនៃការឃុំឃាំងនៅស្ថានីយ៍ប៉ូលីសដោយក្រុមសិទ្ធិមនុស្ស និងអ្នកច្បាប់ ។ ការត្រួតពិនិត្យបែបនេះអាចធ្វើឡើងដោយរួមជាមួយនឹងការបណ្តុះបណ្តាល និងជំនួយបច្ចេកទេសដើម្បីធ្វើឱ្យប្រសើរឡើងនូវជំនាញស៊ើបអង្កេត និងការប្រមូលភស្តុ-តាងរបស់ប៉ូលីស ដើម្បីកាត់បន្ថយនូវការពឹងផ្អែកលើចម្លើយសារភាព។

ផលប្រយោជន៏ជាសក្តានុពលនៃការត្រួតពិនិត្យខាងក្រៅត្រូវបានបង្ហាញឱ្យឃើញតាមរយៈពន្ធ-នាគារនានានៅប្រទេសកម្ពុជា ដែលជាប្រក្រតីត្រូវបានចុះធ្វើទស្សនកិច្ចដោយលីកាដូ និងក្រុមសិទ្ធិមនុស្ស

[៣២] ការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា (UNCOHCHR) បានសំណូមពរថា មាត្រា ៨៥, ៩០, ១៣១, ១៣៨, និង ៥៣៣ នៃសេចក្តីព្រាងក្រមនីតិវិធីព្រហ្មទណ្ឌ គួរតែធ្វើវិសោធនកម្ម ដើម្បីអោយស្របតាមគោលការណ៏នេះ។

និងបុគ្គលិកពេទ្យដទៃទៀត ។ លីកាដូបានរកឃើញថា ការត្រួតពិនិត្យពន្ធនាគារគឺជាវិធីដែលងាយធ្វើជាងគេដើម្បីប្រមូលពត៌មានជាយថាក្រុមផ្តល់ជំនួយ និងទប់ស្កាត់នូវការរំលោភសិទ្ធិមនុស្ស ។ អ្នកត្រួតពិនិត្យផ្សេងៗបាន និងកំពុងចុះធ្វើទស្សនកិច្ចនៅតាមពន្ធនាគារនានាទូទាំងប្រទេសកម្ពុជា ចាប់តាំងពីឆ្នាំ ១៩៩៦ មក ។[៣៣] ការធ្វើទារុណកម្មអ្នកទោសដោយឆ្មាំពន្ធនាគារហាក់ដូចជាមានការថយចុះក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ពោលគឺករណីនៃការធ្វើទារុណកម្មនេះកើតមានចំពោះអ្នកទោស ១២% ដែលសម្ភាសន៍នៅឆ្នាំ ២០០១ និង ០,៤% នៅឆ្នាំ២០០២ តែប៉ុណ្ណោះ ។ ទោះបីជាយ៉ាងណាក្តី ការធ្វើទារុណកម្មដែលគេបានរាយការណ៍ ថាបានប្រព្រឹត្តនៅក្នុងការឃុំឃាំងរបស់ប៉ូលីសមានចំនួនខ្ពស់ជាងច្រើន ។ កត្តាជាឥទ្ធិពលចំពោះភាពមិនស្របគ្នានេះ ទំនងជាបណ្តាលមកពីកង្វះខាតនៃកាត្រួតពិនិត្យ និង សិទ្ធិចេញចូលស្ថានីយ៍ប៉ូលីស ។

ការបើកទូលាយជាទូទៅនូវពន្ធនាគារនៅក្នុងប្រទេសកម្ពុជា គឺជាកិត្តិយសរបស់រដ្ឋាភិបាល និងការបង្ហាញនូវឆន្ទៈរបស់ខ្លួនក្នុងការធ្វើការងារជាមួយអង្គការមកពីខាងក្រៅ ដើម្បីធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសិទ្ធិមនុស្ស និងការគោរពច្បាប់ ។ វាគឺជាគំរូមួយដែលគួរតែយកមកអនុវត្តនៅគ្រប់កន្លែងឃុំឃាំងរបស់ប៉ូលីស ។

## ការសន្និដ្ឋាន

ប្រសិនបើអ្នកត្រូវគេចាប់ខ្លួន ហើយឃុំឃាំងនៅក្នុងស្ថានីយ៍ប៉ូលីសនៅក្នុងប្រទេសកម្ពុជា អ្នកកំពុងតែប្រឈមមុខនឹងគ្រោះថ្នាក់នៃការគំរាមកំហែង និងវាយទាត់ធាក់មិនខាន ។ ការស្រាវជ្រាវរបស់លីកាដូបានរកឃើញនូវកម្រិតគួរឱ្យព្រួយបារម្ភមួយនៃការធ្វើទារុណកម្មរបស់ប៉ូលីស ជាញឹកញាប់នៅថ្នាក់ស្រុកក្នុងអំឡុងនៃការសួរចម្លើយជនសង្ស័យ ។ ជាប្រក្រតីអាជ្ញាធរថ្នាក់លើ និងមន្ត្រីតុលាការមែងធ្វើមិនដឹងមិនឮចំពោះបទល្មើសទាំងនេះ ។

ការពឹងផ្អែកទៅលើការជម្រិតយកចម្លើយសារភាព ហើយនិងការអនុវត្តនូវការជម្រិតយកប្រាក់ពីជនជាប់ឃុំឃាំង គឺជាហេតុផលពីរជាចំបងដែលបណ្តាលឱ្យមានការធ្វើទារុណកម្ម ។ ការដែលប៉ូលីសពឹងផ្អែកទៅលើចម្លើយសារភាព ហើយនិងកង្វះខាតជាទូទៅនូវការស៊ើបអង្កេតមុននឹងធ្វើការចាប់ខ្លួន បានរួមចំណែកយ៉ាងច្រើនសម្បើមចំពោះការកើតមានជាទូទៅនូវការធ្វើទារុណកម្ម ។ បញ្ហាទាំងនេះវាកាន់តែធ្វើឱ្យធ្ងន់ធ្ងរទៅទៀត ដោយហេតុថាតុលាការទទួលយកជាប្រក្រតីនូវចម្លើយសារភាពដោយបង្ខិតបង្ខំ

---

[៣៣] ក្រុមគម្រោងត្រួតពិនិត្យពន្ធនាគារ ធ្វើការងារ ដោយសហការជាមួយក្រុមគ្រូពេទ្យរបស់លីកាដូ ដើម្បីវាយតម្លៃនូវស្ថានភាពសិទ្ធិមនុស្ស ហើយនិង សុខមាលភាពជាទូទៅរបស់អ្នកទោស ។

ធ្វើជាភស្តុតាង ហើយនិងប្រការដែលថាអ្នកធ្វើទារុណកម្មដែលជាប៉ូលីសនោះកម្រត្រូវគេស៊ើបអង្កេត ដាក់វិន័យ ឬយកមកផ្តន្ទាទោសទោសណាស់ ។ រដ្ឋាភិបាលកម្ពុជាចាំបាច់ត្រូវធ្វើការប្រឹងប្រែងរួមគ្នាជាបន្ទាន់មួយក្នុងការដោះស្រាយ មូលហេតុនៃការធ្វើទារុណកម្មទាំងនេះ ដើម្បីកាត់បន្ថយនូវការធ្វើទារុណកម្មនៅក្នុងការឃុំឃាំងរបស់ប៉ូលីស និងដើម្បីធានានូវការដាក់ទណ្ឌកម្មចំពោះអ្នកប្រព្រឹត្តអំពើទារុណកម្មទៅតាមច្បាប់ ។ លើសពីនេះ លីកាដូ មានជំនឿថា ការមានសិទ្ធិចេញចូលស្ថានីយ៍ប៉ូលីសកាន់តែច្រើន ដើម្បីធ្វើការត្រួតពិនិត្យដោយឯករាជ្យជាទៀងទាត់នូវស្ថានភាពនៃការឃុំឃាំង ក៏មានការចាំបាច់យ៉ាងខ្លាំងដើម្បីការពារជនជាប់ឃុំឃាំងអំពីការរំលោភបំពានផ្សេងៗ ។

## អនុសាសន៍

លីកាដូ ទទួចសុំឱ្យមានវិធានការដូចខាងក្រោម ÷

***ចំពោះរាជរដ្ឋាភិបាលកម្ពុជា :***

- ធ្វើឱ្យប្រាកដថា សេចក្តីព្រាងក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌថ្មី មានមានចែងយ៉ាងជាក់លាក់នូវបញ្ញត្តិផ្សេងៗដែលបំពេញនូវកាតព្វកិច្ចទាំងអស់របស់ប្រទេសកម្ពុជា ដែលបានចុះហត្ថលេខាលើអនុសញ្ញាអន្តរជាតិប្រឆាំងការធ្វើទារុណកម្ម និងការផ្តន្ទាទោស ឬការប្រព្រឹត្តិទាំងឡាយណាដែលឃោរឃៅ អមនុស្សធម៌ ឬដែលនាំឱ្យបាត់បង់តម្លៃជាមនុស្ស ។
- ដើម្បីឱ្យប្រាកដថា ច្បាប់ព្រហ្មទណ្ឌថ្មី ហើយនិងបទបញ្ញត្តិរបស់ប៉ូលីសដែលអាចអនុវត្តបានធានានូវសិទ្ធិរបស់មនុស្សគ្រប់រូប ដែលស្ថិតនៅក្រោមការចាប់ខ្លួនក្នុងការទំនាក់ទំនងជាមួយតំណាងផ្លូវច្បាប់ ហើយនិងសុំឱ្យមានរបស់តំណាងនោះក្នុងអំឡុងពេលនៃការសួរចម្លើយណាមួយដោយប៉ូលីស ។ ច្បាប់និងបទបញ្ញត្តិទាំងនោះ ក៏គួរតែធានានូវសិទ្ធិរបស់ជនជាប់ចោទក្នុងការធ្វើទំនាក់ទំនងជាមួយមិត្តភ័ក្រ្ត ញាតិសន្តាន អ្នកការពារសិទ្ធិមនុស្ស ឬក៏មនុស្សដទៃទៀតក្នុងខណៈពេលដែលខ្លួនស្ថិតនៅក្នុងការឃុំឃាំង ។
- ផ្តល់ការអនុញ្ញាតដល់អង្គការសិទ្ធិមនុស្ស និងច្បាប់ក្នុងការចុះទៅទស្សនកិច្ចឱ្យបានទៀងទាត់នៅទៅទីកន្លែងឃុំឃាំងផ្សេងៗរបស់ប៉ូលីស ដើម្បីត្រួតពិនិត្យស្ថានភាពនៃការឃុំឃាំង និងការប្រព្រឹត្តទៅលើជនជាប់ឃុំឃាំង ។
- ចាត់វិធានការទាំងអស់ដែលចាំបាច់ ដើម្បីធ្វើឱ្យប្រាកដថាមន្ត្រីសាធារណៈណាម្នាក់ដែលប្រព្រឹត្តចូលរួម ឬក៏រួមគំនិតតាមរូបភាពណាមួយនៅក្នុងអំពើទារុណកម្ម ឬក៏អំពើ

ឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោកតម្លៃមនុស្សផ្សេងៗត្រូវបានផ្តន្ទាទោសទៅតាមច្បាប់ ។

- ផ្តល់នូវការបណ្តុះបណ្តាលដែលមានប្រសិទ្ធិភាព ចំពោះតុលាការ ភ្នាក់ងារប៉ូលីស និងមន្ត្រីទាំងអស់ ដែលពាក់ព័ន្ធនឹងការឃុំឃាំង សួរចម្លើយ ឬការព្យាបាលមនុស្សដែលស្ថិតនៅក្នុងការឃុំឃាំងរបស់ប៉ូលីស ។ បន្ថែមពីលើការអប់រំអំពីច្បាប់ ការបណ្តុះបណ្តាលគួរតែផ្តោតទៅលើការផ្តល់ដល់ប៉ូលីសនូវជំនាញផ្សេងៗទៀតក្នុងការប្រមូលភស្តុតាងជាជាងពឹងផ្អែកទៅលើចម្លើសារភាព។

***ចំពោះអង្គការក្រៅរដ្ឋាភិបាលកម្ពុជា និងអន្តរជាតិ :***

- ធ្វើការប្រឹងប្រែងរួមគ្នា ដើម្បីកត់ត្រាជាឯកសារនូវករណីនៃការធ្វើទារុណកម្មនៅក្នុងការឃុំឃាំងរបស់ប៉ូលីស ហើយចាត់វិធានការជាបន្ទាន់ប្រឆាំងនឹងការរំលោភបំពានរបស់ប៉ូលីស។
- ពង្រឹងនូវកម្មវិធីបណ្តុះបណ្តាលស្តីអំពីគោលការណ៍នៃសិទ្ធិមនុស្ស និងច្បាប់ ជាពិសេសចំពោះគោលការណ៍ដែលទាក់ទងនឹងការចាប់ខ្លួនការឃុំឃាំង និងការសួរចម្លើយសម្រាប់ប៉ូលីស យោធា និងមន្ត្រីតុលាការនៅទូទាំងប្រទេស។
- ចុះធ្វើទស្សនកិច្ចទៅកាន់កន្លែងឃុំឃាំងឱ្យបានទៀងទាត់ ដោយកត់ត្រាជាឯកសារ និងផ្សព្វផ្សាយអំពីលទ្ធផលផ្សេងៗ។

***ចំពោះរដ្ឋាភិបាលបរទេស និងទីភ្នាក់ងារផ្តល់ជំនួយ :***

- ទទូចរដ្ឋាភិបាលកម្ពុជា ចាត់វិធានការ ដូចបានលើកជាអនុសាសន៍ចំពោះរដ្ឋាភិបាលខាងលើប្រឆាំងនឹងការអនុវត្តនូវអំពើទារុណកម្ម នៅក្នុងការឃុំឃាំងរបស់ប៉ូលីស។
- គាំទ្រចំពោះអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ ទាក់ទងនឹងអនុសាសន៍ទាំងនេះ ព្រមទាំងផ្តល់នូវការគាំទ្រផ្នែកភស្តុភា និងហិរញ្ញវត្ថុ ចំពោះគម្រោងនានាដែលសំដៅទៅលើការកាត់បន្ថយការធ្វើទារុណកម្ម។

អាស្រ័យដោយធនធានមានកម្រិត និងកង្វះខាតការិយាល័យអចិន្ត្រៃយ៍ ពន្ធនាគារនៅក្នុងបណ្តាខេត្តខាងក្រោមមិនត្រូវបានបញ្ចូលទៅក្នុងកម្មវិធីត្រួតពិនិត្យពន្ធនាគាររបស់លីកាដូឡើយ។ ខេត្តទាំងនោះ រួមមានរតនគីរី មណ្ឌលគីរី ក្រចេះ ស្ទឹងត្រែ និងព្រះវិហារ។

របាយការណ៍របស់រដ្ឋាភិបាលកម្ពុជា អំពីអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងការធ្វើទារុណកម្ម និងការផ្តន្ទាទោសឬការប្រព្រឹត្តទាំងឡាយណាដែលឃោរឃៅ អមនុស្សធម៌ ឬដែលនាំឱ្យបាត់បង់តម្លៃជាមនុស្ស ឆ្នាំ២០០៣ ទំព័រ៤

បន្ថែមពីលើការធ្វើទារុណកម្ម អនុសញ្ញាក៏ហាមប្រាម"ការធ្វើទារុណកម្ម និការផ្តន្ទាទោស ឬការប្រព្រឹត្តទាំងឡាយណាដែល ឃោរឃៅ អមនុស្សធម៌ ឬដែលនាំឱ្យបាត់បង់តម្លៃជាមនុស្ស ដែលមិនត្រូវបានគេសន្មត់ថាជាការធ្វើទារុណកម្មទេនោះ" (មាត្រា ១៦)។ អំពើបែបនេះមិនត្រូវបានកំណត់និយមន័យឡើយ លើកលែងតែប្រការដែលថាវាត្រូវបានប្រព្រឹត្តដោយ ឬដោយជាមួយនឹងការយល់ព្រម ឬការគាំទ្ររបស់មន្ត្រីសាធារណៈណាម្នាក់។

រដ្ឋអំណាចផ្នែកចាប់ចង ជាទូទៅគឺភ្នាក់ងារប៉ូលីស ប៉ុន្តែក្នុងករណីមួយចំនួន គឺជាយោធា ឬមន្ត្រីដទៃទៀត ហើយកន្លែងនៃការឃុំឃាំង មិនមែនជាកន្លែងឃុំឃាំងរបស់ប៉ូលីសទេ គឺជាបន្ទាយយោធា ឬស្ថាប័នផ្សេងទៀត។

សូមមើលមាត្រា៣៦ នៃច្បាប់នីតិវិធីព្រហ្មទណ្ឌ ដែលរៀបរាប់អំពីមន្ត្រីដែលត្រូវបានចាត់ទុកជាភ្នាក់ងារនគរបាលយុត្តិធម៌។

អនុក្រិត្យលេខ៧៧ ឆ្នាំ១៩៩៤ ស្តីអំពីតួនាទី-ភារកិច្ចនិងរចនាសម្ព័ន្ធទូទៅនៃកងរាជអាវុធហត្ថ។ ទោះបីជាយ៉ាងណា វិសោធនកម្មទៅលើច្បាប់នីតិវិធីព្រហ្មទណ្ឌ (មាត្រា៣៦) ខែមករា ២០០២ បានកាត់បន្ថយអំណាចរបស់អង្គភាពកងរាជអាវុធហត្ថ ដែលទទួលបន្ទុកផ្នែកព្រហ្មទណ្ឌមកត្រឹមបទល្មើស ដែលទាក់ទងនឹងកិច្ចការយោធាតែប៉ុណ្ណោះ។

បទសម្ភាសន៍ រួមមានជាមួយអ្នកជាប់ឃុំបណ្តោះអាសន្ន និងទណ្ឌិត។ សំណួរដែលសួរគឺ: "តើអ្នកត្រូវគេបំភិតបំភ័យ គំរាមកំហែង ឬធ្វើទារុណកម្ម ក្នុងរូបភាពណាមួយដែរឬទេ នៅពេលដែលស្ថិតនៅក្នុងកន្លែងឃុំឃាំងរបស់ប៉ូលីស?" អ្នកដែលឆ្លើយថា "មាន" ត្រូវបានសុំឱ្យពណ៌នា ពីការធ្វើទុក្ខបុកម្នេញ ដែលខ្លួនចោទប្រកាន់នោះ។
បទសម្ភាសន៍របស់រៀបឯកសារនេះ ជាមួយនិងតំណាង LAC មកពីខេត្ត ចំនួន៧គឺ: កោះកុង កំពង់ចាម ភ្នំពេញ កំពង់សោម សៀមរាប កណ្តាល និងខេត្តស្វាយរៀង។

អាស្រ័យដោយធនធានមានកម្រិតកាលពីឆ្នាំ២០០២ ពត៌មានដែលបានមកពីការសម្ភាសន៍អ្នកទោស មិនទាន់ត្រូវបានបញ្ចូលទៅមកក្នុងតារាងទិន្នន័យរបស់លីកាដូនៅឡើយ ហើយមិនអាចធ្វើការវិភាគជាបន្តទៀតនៅឡើយ។

អ្នកផ្តល់ចម្លើយចំនួន២៩នាក់ មិនត្រូវបានបញ្ចូលក្នុងតារាងនេះទេ អាស្រ័យដោយការពណ៌នាថាមានការធ្វើទារុណកម្មនោះ មិនមានភាពគ្រប់គ្រាន់។

អាស្រ័យដោយពត៌មាននេះ បានផ្តល់នូវសន្ទស្សន៍មួយពីភាពធ្ងន់ធ្ងរនៃការប្រើអំពើហិង្សា នោះសុខភាពពីមុនរបស់ជនរងគ្រោះក៏គួរតែត្រូវបានយក មកពិចារណាដែរ។

រដ្ឋធម្មនុញ្ញកម្ពុជា (មាត្រា៣៨) និងច្បាប់ព្រហ្មទណ្ឌអន្តរកាល(មាត្រា២៤, ៣) បានហាមឃាត់ មិនឱ្យប្រើប្រាស់ចម្លើយសារភាពដោយបង្ខំ ជាភស្តុតាងនៅក្នុងតុលាការ។ លើសពីនេះ នៅក្រោមច្បាប់ព្រហ្មទណ្ឌ ទោះបីជាគមានភស្តុតាងថាចម្លើយសារភាពនោះមិនមែនបានមកដោយការបង្ខំក្តីគេមិនអាចប្រើវា ដើម្បីកាត់ទោសជនជាប់ចោទឱ្យជាប់ពន្ធនាគារឡើយ លុះត្រាតែវាមានភស្តុតាងផ្សេងទៀតមកបញ្ជាក់បន្ថែម។

ច្បាប់ព្រហ្មទណ្ឌអន្តរកាលឆ្នាំ១៩៩២(មាត្រា១៣) ច្បាប់ស្តីអំពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៩៣ (មាត្រា៤៧)

វិសោធនកម្មខែវិច្ឆិកាឆ្នាំ២០០១នៃមាត្រា៣៨ នៃច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ(១៩៩៣)។ ការពន្យាពេល២៤ម៉ោងនៃការឃុំឃាំង សម្រាប់ប្រើប្រាស់នៅក្នុងកាលៈទេសៈមួយចំនួនប៉ុណ្ណោះ ក្នុងនោះរួមមាន ÷ បទឧក្រិដ្ឋធ្ងន់ធ្ងរ ភស្ដុតាងច្បាស់លាស់ដែលទម្លាក់ការចោទប្រកាន់ទៅលើជនសង្ស័យ ហើយនិងការឯកភាពជាលាយល័ក្ខណ៍អក្សរពីព្រះរាជអាជ្ញា។
ប៉ូលីសត្រូវបានអនុញ្ញាតឱ្យធ្វើការចាប់ខ្លួនដោយគ្មានដីការបង្គាប់នូវមនុស្សម្នាក់ដែលត្រូវគេចាប់បានក្នុងពេលប្រព្រឹត្តបទឧក្រិដ្ឋ (មាត្រា ៣៥ នៃច្បាប់ស្ដីអំពីនីតិវិធីព្រហ្មទណ្ឌ និងមាត្រា ១៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល)។ គួរយកមកពិចារណាផងដែរនូវប្រការដែលថា អ្នកជាប់ឃុំឃាំងខ្លះនៅក្នុងចំណាត់ប្រភេទនេះ អាចមានវត្តមាននៅកន្លែងដែលឧក្រិដ្ឋកម្មមួយកើតឡើង ប៉ុន្តែត្រូវគេយល់ច្រឡំថាជាជនល្មើស។

របាយការរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ស្ដីអំពីអនុសញ្ញាអន្តរជាតិប្រឆាំងការធ្វើទារុណកម្ម និការផ្ដន្ទាទោស ឬការប្រព្រឹត្តទាំងឡាយណាដែលឃោរឃៅ អមនុស្សធម៌ ឬដែលនាំឱ្យបាត់បង់តម្លៃជាមនុស្ស, ឆ្នាំ២០០៣, ទំព័រ១២៤
ប៉ូលីសជាតិនៃកម្ពុជា សៀវភៅនីតិវិធីប៉ូលីសច្បាប់ ទំព័រ៣-១៧ និង៣-៥០
ច្បាប់ព្រហ្មទណ្ឌអន្តរកាល (មាត្រា១០)
ច្បាប់ស្ដីអំពីនីតិវិធីព្រហ្មទណ្ឌ (មាត្រា៧៥)
ប៉ូលីសជាតិនៃកម្ពុជា សៀវភៅនីតិវិធីប៉ូលីសតុលាការ។ ទំព័រ៣-១៧

នៅក្នុងបទសម្ភាសន៍របស់លីកាដូ ទាំងអ្នកជាប់ឃុំឃាំងមុនពេលជំនុំជំរះក្ដី និងអ្នកទោសត្រូវបានសាកសួរអំពីតំណាងផ្នែកច្បាប់របស់ពួកគេ ៖ អ្នកជាប់ឃុំឃាំងមុនពេលជំនុំជំរះក្ដីត្រូវបានសួរថា តើពួកគេមានមេធាវីឬអត់ នៅពេលសម្ភាសន៍នោះ ហើយអ្នកទោសត្រូវបានសួរថា តើគេមានមេធាវី ឬអត់ នៅពេលឡើងទៅតុលាការកាត់ក្ដី។
កង្វះខាតមេធាវីនៅក្នុងប្រទេសកម្ពុជា បានធ្វើឱ្យបញ្ហានេះរិតតែធ្ងន់ធ្ងរទៅទៀត។

សំណុំរឿងនេះទាក់ទងនឹងសិស្សវិទ្យាល័យពីរនាក់ដែលត្រូវគេចាប់ខ្លួន និងវាយធ្វុនៗដោយប៉ូលីសបីនាក់ ដែលស្រវឹងស្រា ដើម្បីបង្ខំឱ្យពួកគេសារភាពចំពោះការវាយប្រហារដែលមិនសមស្រប។ ក្រោយមកសិស្សទាំងនោះត្រូវបានដោះលែងដោយគ្មានការចោទប្រកាន់អ្វីឡើយ ។ ប៉ូលីសត្រូវបានកាត់ទោសអំពីបទវាយប្រហារលើរាងកាយ ដោយត្រូវជាប់ពន្ធនាគារព្យួរទោសចំនួនបីខែ និងត្រូវបានបញ្ជាឱ្យសងជម្ងឺចិត្តរួមគ្នា ចំនួន ១៧៥ ដុល្លារ ទៅឱ្យគ្រួសារជនរងគ្រោះ។ សូមអានព្រឹត្តិប័ត្រប្រចាំត្រីមាសរបស់ជំនួយការផ្នែកច្បាប់នៃកម្ពុជាលេខ ៤ ខែ កុម្ភៈ ឆ្នាំ២០០៣។

កងរាជអាវុធហត្ថត្រូវបានចោទប្រកាន់ និងដាក់ទោសពីបទវាយប្រហារលើរាងកាយ ប៉ុន្តែមិនមែនពីបទមនុស្សឃាតឡើយ។ គាត់បានទទួលទោសជាប់ពន្ធនាគាររយៈពេលពីរឆ្នាំ ប៉ុន្តែបានជាប់ឃុំពិតប្រាកដតែបួនខែប៉ុណ្ណោះ ហើយរយៈពេលក្រៅពីនោះត្រូវព្យួរទោស។ សូមមើលរបាយការណ៍ "អន់ជាងមនុស្ស: ការធ្វើទារុណកម្មនៅក្នុងប្រទេសកម្ពុជា" របស់លីកាដូ ខែ មិថុនា ឆ្នាំ២០០០ ទំព័រ ១០៤។

បទសម្ភាសន៍ជាមួយមេធាវីជំនួយផ្នែកច្បាប់នៃកម្ពុជា។

តំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិដើម្បីសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា "ការចងព្យួរតាមដងផ្លូវនៅក្នុងប្រទេសកម្ពុជា" ថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ២០០២ និង "ស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា" ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ២០០២ (កថាខ័ណ្ឌ១៦)

រដ្ឋធម្មនុញ្ញ (មាត្រា៣៨)
ច្បាប់ព្រហ្មទណ្ឌអន្តរកាល(មាត្រា២២, ២ និង៥៧)
រដ្ឋធម្មនុញ្ញ (មាត្រា៣៨, ៥) និងច្បាប់ព្រហ្មទណ្ឌអន្តរកាល (មាត្រា២៤,៣)
មាត្រា៧ និង៩
សូមមើលច្បាប់ព្រហ្មទណ្ឌអន្តរកាល (មាត្រា៦, ១)

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា (UNCOHCHR) បានសំណូមពរថា មាត្រា ៨៥, ៩០, ១៣១, ១៣៨, និង ៥៣៣ នៃពង្រាងច្បាប់នីតិវិធីព្រហ្មទណ្ឌគួរតែធ្វើវិសោធនកម្ម ដើម្បីអនុលោមតាមគោលការណ៍នេះ។

ក្រុមគម្រោងត្រួតពិនិត្យពន្ធនាគារ ធ្វើការងារ ដោយសហការជាមួយក្រុមគ្រូពេទ្យរបស់លីកាដូ ដើម្បីវាយតម្លៃនូវស្ថានភាពសិទ្ធិមនុស្ស ហើយនិងសុខមាលភាពជាទូទៅរបស់អ្នកទោស។